ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី៣ ឆ្នាំ២០២១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ




ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

# គតិបណ្ឌិតរដ្ឋបុរសជាតិ

« ការគោរពឱ្យបានខ្ជាប់ខ្ជួន នូវក្រមសីលធម៌វិជ្ជាជីវៈពេទ្យ
ការផ្តល់សេវាសុខភាព និងការជួយស្រោចស្រង់ជីវិតមនុស្ស
គឺជាអំពើមនុស្សធម៌ដ៏ខ្ពង់ខ្ពស់បំផុត។ »

**សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
ឆ្នាំ២០០១

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង
- ឃឹម ណុលសន

និពន្ធនាយក
- អ៊ីវ ចុង

ការិយាល័យនិពន្ធ
- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋ-កិច្ច សង្គមកិច្ច និង វប្បធម៌

អ្នកចាត់ចែងផលិត
- ប៉ិច សុខា
- អ៊ិន តុលា

អ្នកចែកផ្សាយ
- អៀង រដ្ឋា
- សេក វុទ្ធី

ការីកុំព្យូទ័រ
- អេង វត្ថមុនី
- សយ វាស្នា
- ឃឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**

I- បទអត្ថាធិប្បាយ មនុស្សជាទាសករអតីតកាលឬ? ១-៤

II- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទបញ្ញត្តិបច្ចេកទេសសំណង់ និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទបញ្ញត្តិបច្ចេកទេសសំណង់ ៥-៧

២- សេចក្តីព្រាងអនុក្រឹត្យនៃការគ្រប់គ្រងការប្រមូលហៅម្ហូបអាហារត្រឡប់មកវិញ ៨

៣- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា ៩-១០

III- បទវិភាគ៖

១- ប្រទេសចិន៖ គូប្រជែងដែលមានឥទ្ធិពលនយោបាយ និងថាមពលយោធាគ្រប់គ្រាន់ទប់ទល់ជាមួយនឹងនយោបាយជ្រៀតជ្រែករបស់សហរដ្ឋអាមេរិក ១១-១២

២- ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនានាដែលឆ្លុះបញ្ចាំងពីរដ្ឋប្រហារនៅភូមាទម្លាក់លោកស្រី អ៊ូង សានស៊ូជី ១៣-១៤

IV- ការសិក្សា

- កំណើតល្បែងប្រណាំងទូក ង និង ការប្រណាំងទូក ង នៅកម្ពុជាក្រោម ១៥-២១

V- នាទីវប្បធម៌

១- បច្ចេកសព្ទអំពីទម្រង់ផ្សេងៗនៃកសិកម្ម ២២-២៣

២- ស្វែងយល់អំពីពាក្យ បណ្តៅ ២៤-២៩

VI- នាទីកំណាព្យ

- កង្កែបចង់បានស្តេច (ពាក្យ៧) ៣០

VII- នាទីកំសាន្ត

- ល្បើកទន្សាយនិងត្រីរស់ ៣១

# មនុស្សជាទាសករអតីតកាលឬ?

គេតែងពោលសរសើរមនុស្សថាមានគុណសម្បត្តិប្រសើរ មានលក្ខណៈដាច់ដោយឡែកពីសត្វតិរច្ឆាន ដែលរស់នៅក្នុងសភាវគតិ។ សភាវគតិនេះត្រូវបានសត្វទទួលតាំងពីកំណើត តាមពូជប្រភេទរបស់វា ហើយបានរីកចម្រើនដុះដាលអស់ត្រឹមការបង្ហាត់បង្ហាញដែលសត្វបានទទួលពីមេឬសង្គមប្រភេទដូចគ្នា។សត្វទាំងឡាយមិនអាចរំកិលជីវិតវានៅចន្លោះអតីតកាលនិងអនាគតកាលទេ សភាវគតិបានកំណត់ជីវិតសត្វតិរច្ឆានឱ្យរស់ក្នុងបច្ចុប្បន្នសឹងតែសុទ្ធសាធ។

កុមារកើតក្នុងត្រកូលមានម្ដាយឪពុក ទទួលការអប់រំក្នុងគ្រួសារ ក្នុងសាលា ក្នុងសង្គម។ បើតាមពួកចិត្តវិទូ សង្គមវិទូ អនុភាពនៅជុំវិញខ្លួននេះបានជ្រាបចូលទៅក្នុងសាច់ឈាមរបស់ក្មេង ហើយកាលបើវាធំពេញវ័យអនុភាពនេះជំរុញបុគ្គលឱ្យធ្វើសកម្មភាពក្នុងអំណាចនៃអតីតកាលដែលខ្លួនបានទទួលឬបើនិយាយឱ្យងាយស្ដាប់តាមទស្សនៈខាងលើថាមនុស្សជាកញ្ជះអតីតកាលរបស់ខ្លួន។ព្រមពេលជាមួយនេះបញ្ហាសេរីភាពរបស់មនុស្សក៏ត្រូវមានចំណោទ។ មនុស្សសង្ស័យនឹងទង្វើរបស់ខ្លួនថា តើខ្លួនធ្វើអ្វីៗនោះ ពិតជាចេញមកអំពីខ្លួនពិតប្រាកដ ឬក៏នៅក្រោមបញ្ជាអតីតកាលសុទ្ធសាធ។ ក្នុង គំហើញទស្សនវិជ្ជា កាលបើបញ្ហានេះត្រូវបានចោទមកហើយ សេរីភាពរបស់មនុស្សក៏ត្រូវកំហែងគំរាមពិតប្រាកដ។

ក្នុងសម័យចុងក្រោយនៃសតវត្សទី២០នេះ វិទ្យាសាស្ត្របានស្គាល់ការរីកចម្រើនយ៉ាងមហិមា មនុស្សលើកយកវត្ថុធាតុនៅក្នុងលោកមកសិក្សាដល់ទីជម្រៅក្រៃលែង ដោយបែងចែកពិភពលោកទៅជាធាតុដ៏ល្អិត ហើយផ្គុំធាតុទាំងនេះតាមច្បាប់របស់វាឲ្យចេញជាផលវិទ្យាសាស្ត្រតាមទំនាក់ទំនងហេតុនិងបច្ច័យ។ពិតមែនតែវិទ្យាស្សង់នៅមានអាយុក្មេងមែន បើប្រៀបទៅអាយុមនុស្សជាតិ តែអនុភាពរបស់វាបានរីកចម្រើនធាត់ធំធំពន់ប្រមាណ ហើយមនុស្សជាតិ កំពុងភិតភ័យនឹងវណ្ណកម្មរបស់ខ្លួនទៀតផង។ តថភាពមនុស្សក្នុងវត្ថុតិចនិកបានក្លាយទៅជាវត្ថុកំរោលបាញ់ឆ្ពោះទៅរកការប្រល័យលោកជាងការស្ថាបនាមនុស្សនេះគឺជាការកំហែងគំរាមមួយទៀតលើវាសនាមនុស្សក្នុងអនាគត។លុះដោយអំណាចនៃសច្ចៈវិទ្យាស្សង់ ចិត្តវិទូ សង្គមវិទូ និងអ្នកវិទ្យាសាស្ត្រឯទៀតមានសេចក្ដីទុកចិត្តទាំងស្រុងលើសមត្ថភាពរបស់ស្សង់ថានឹងយកមនុស្សជាវត្ថុសិក្សាបានមិនខុសពីវត្ថុឯទៀតឡើយ។ លោក ឡាម៉ាក់ ( Lamark ) និងលោក ដាវិន ( Darwin ) ដែលជាអ្នកបង្កើតទ្រឹស្ដីកម្លាយរូប ( Théorie transformiste ) បានអះអាងថា មនុស្សមានកំណើតពីសត្វតិរច្ឆានដោយអំណាចនៃការវិវត្តលោក។ លោក ថីឡាដឺសាកដាំង ( Theilard de Chardin ) បានធ្វើបរមត្ថវិជ្ជាពីដុំថ្ម ដើម្បីចង្អុលឲ្យឃើញថាមនុស្សមានកំណើតពីជាតិដី ស្រទាប់ដីម៉្យាង ( Biosphère ) ធ្វើឲ្យកើតមនុស្ស។

«ដើម្បីអាចយល់ឲ្យបានត្រឹមត្រូវពីការិយកម្មនៃគំនិតបាន ត្រូវចាត់ទុកខួរក្បាលជាសរីរាង្គពិសេសសម្រាប់បង្កើតគំនិត ដូចជាក្រពះនិងពោះវៀនសម្រាប់ការរំលាយអាហារ ហើយប្រមាត់សម្រាប់ច្រងបញ្ចេញទឹកប្រមាត់ដូចនេះដែរ។ ខួរក្បាលកិនរំលាយអរម្មណ៍ ហើយបញ្ចេញជាគំនិតមកក្រៅ។ លោក កាបានីស ( Cabanis ) លោក កាល់ វកត៍ ( Karl Voct ) សុទ្ធសឹងជាអ្នកជាវិននិយមបានសង្កត់ពាក្យថា ៖ ខួរក្បាលបញ្ចេញគំនិតដូចប្រមាត់បញ្ចេញទឹកប្រមាត់ វក្កំបញ្ចេញទឹកមូត្រ »។

ចិត្តវិភាគលោក ហ្វ្រីដ៍ (Simung Freud) ចែកអត្តមនុស្សជាបីកម្រិត ៖ le ça ឬ le soi ជាភាវៈដើមនៃអត្តដែលមានសភាវៈជាធាតុ le soi នេះស្ថិត នៅដាច់ពីលោកខាងក្រៅក្នុងន័យវាជាភាវៈមួយនៅតែក្នុងកាយ វាមិនមានសកម្មភាពនៅក្រៅកាយ តែផ្នែកមួយរបស់វាដែលប៉ះនឹងលោកខាងក្រៅហៅថា le moi ។ le moi នេះជាភាវៈនៃគំនិត រីឯ le sur-moi ជាអត្តៈដែលទទួលការបន្ថែមមួយដែលមិនមែនជាធម្មជាតិ។ គឺជា le moi មកលើ le moi ។ le moi ក្លាយជា le sur-moi ដែលចាំកំញើញ បញ្ជា ត្រួតពិនិត្យ le moi ក្នុងគ្រប់សកម្មភាព។ សរុបសេចក្តីទៅ le moi ត្រូវកៀបសង្កត់ដោយ le ça ដែលមានសភាវៈម្នាក់ម្ខាងនិង le sur-moi ម្ខាងទៀតដែលជាផលនៃអតីតកាល។

តាមទ្រឹស្តីរូបនិយមបដិសំយោគ (théorie matérialiste dialectique) លោក កាល់ ម៉ាក់(Karl Marx) វិញថា «មនុស្សជាផលិតផលនៃប្រវត្តិសាស្ត្រ» យើងដឹងថាប្រវត្តិវិទ្យាមានគំហើញក្នុងអតីតកាល។ គាត់ពោលម្យ៉ាងទៀតថា : គំនិតមនុស្សប្រែប្រួលទៅតាមការផ្លាស់ប្តូរនៃលក្ខខណ្ឌជីវិត ទំនាក់ទំនងក្នុងសង្គម ការរស់នៅនៃសង្គម។ ហេដ្ឋារចនាសម្ព័ន្ធកំណត់ឧបរចនាសម្ព័ន្ធ ( l ΄ infrastructure détermine la super structure) ឬរចនាសម្ព័ន្ធសេដ្ឋកិច្ចកំណត់ចិត្តគំនិតសង្គម។ តាមទ្រឹស្តីគាត់គឺ «រូបបង្កើតគំនិត»។

តាមលោកឌៀខេម (Durkheim) ឯកត្តបុគ្គលត្រូវក្រសោបដោយសង្គមអ្វីៗដែលយើងគិត យើងធ្វើជាអំណោយរបស់សង្គម។បុព្វហេតុកំណត់សង្គមការណ៍មួយបានត្រូវរុករកក្នុងចំណោមសង្គមការណ៍ទាំងឡាយពីមុន មិនមែនក្នុងចំណោមសភាពនៃសម្បជញ្ញៈឯកត្តជននោះឡើយ។ សង្គមច្រើនជាសភាពពិតរបស់គំនិតជាងសភាពពិតនៃសម្ភារៈ ហើយនៅមានតថភាពសីលធម៌មួយនៅខាងក្រៅសម្បជញ្ញៈឯកត្តជន និងនៅខាងក្រៅសម្បជញ្ញៈរបស់ទស្សនវិទូ ដែលជាអ្នករាវរករបៀបពន្យល់និងសម្តែងនូវសភាពពិតនេះទៅទៀត។ តាមទស្សនៈនេះសង្គមមនុស្សធំធេងណាស់វាក្រសោបមិនតែបុគ្គលដែលរស់នៅក្នុងអាណាចក្ររបស់វាដោយមិនគិតនោះទេ សូម្បីតែទស្សនវិទូដែលចេះយកបញ្ហាសង្គមមកចោទក៏ហក់មិនផុតពីសង្គមដែរ គំនិតរបស់ គាត់គ្រាន់តែជាចំណាំងនៃគំនិតរបស់សង្គមប៉ុណ្ណោះ។

ចំពោះបញ្ហានេះ លោក ឡេវី ប្រ៊ុល (Lévy Bruhl) យល់មិនជាខុសពីលោក ឌៀខេម ប៉ុន្មានទេ ចំពោះគាត់ឯកត្តជនត្រូវស្រូបទៅក្នុងក្រុមហើយបុគ្គលខ្លួនឯងមិនទាំងសូវបានចាប់ក្លឹកថាខ្លួនឯងនោះជាសមាជិកនៃក្រុមរបស់ខ្លួនផងទេ។

បើតាមការពិនិត្យតើគំហើញរបស់អ្នកវិទ្យាស្សង់ចំពោះធម្មជាតិមនុស្ស យើងឃើញមនុស្សមិនជាវត្ថុដ៏អាថ៌កំបាំងអ្វីទេគេអាចរកការពិតរបស់វាបាន ហើយគេប្រហែលនឹងអាចស្ថាបនាមនុស្សម៉ាស៊ីនឬម៉ាស៊ីនមនុស្សដែលមានគុណសម្បត្តិដូចមនុស្សបាន« cybernétique – Aurel David » ក្នុងពេលមិនយូរប៉ុន្មាន។ តែពួកអ្នកវិទ្យាស្សង់តែងរំលងសញ្ញាណមនុស្ស «les savants ont toujours sauté le problème de la conscience » ។ កាលបើគេថាមនុស្សកើតពីសត្វគឺសញ្ញាណនេះឯងជាអ្នកថាសញ្ញាណនេះហើយដែលបានបង្កើតទ្រឹស្តីកម្លាយរូប លុបមនសិការចេញពីមនុស្ស ទ្រឹស្តីកម្លាយរូបក៏គ្មានដែរ។ មានតែមនុស្សដែលចេះពោលថាមនុស្សកើតពីសត្វឯសត្វតិរច្ឆានវិញគ្មានគំនិតនោះឡើយមនសិការជាមហាសមុទ្រខណ្ឌផ្តាច់មនុស្សពីសត្វក្នុងពិភពគំនិត។ ធ្វើបរមត្ថវិជ្ជាមនុស្សពីដុំថ្មពិតជាល្បែងកំសាន្ត។បើថ្ងៃនេះខ្ញុំថា «មនុស្សជាផលិតផលនៃប្រវត្តិសាស្ត្រ»ថ្ងៃក្រោយខ្ញុំនឹងថាផ្សេងពីនេះ ព្រោះប្រវត្តិសាស្ត្រថ្ងៃស្អែកមិនមែនប្រវត្តិសាស្ត្រពីម្សិលមិញទេ។ទ្រឹស្តីលោក ហ្វ្រីដ៍ អនុវត្តបានផលខ្លះតែចំពោះជាតិខ្លះ ក្នុងរដ្ឋខ្លះ នៅអឺរ៉ុបខាងជើងប៉ុណ្ណោះ។ ចិត្តវិភាគសិក្សាតែករណីមិនធម្មតារបស់

មនុស្ស (en cas de névrose ou pathologique) គឺមនុស្សធម្មតាជាអ្នកសិក្សាមនុស្សមិនធម្មតា ដូចនេះ ចិត្តវិភាគមិនអាចទូទៅទេ។

មានទស្សនវិទូជាច្រើនមានទស្សនៈប្លែក ពីទ្រឹស្តីទាំងឡាយខាងលើ លោក នីតឆ៍ (Nietzche) ដែលលុះដោយទ្រឹស្តីកម្លាយរូបរបស់លោក ដារិន មែន ហើយប្រឆាំងនឹងអ្នកប្រាជ្ញទាំងឡាយខាងផ្នែកចរិយាធម៌ការពារពួកជនទន់ខ្សោយ តែត្រិះអស្តិរូបនៃសកម្មភាពនិងតម្លៃសត្វរបស់គាត់ បានជំរុញសត្វឲ្យហក់ចេញពីខ្លួនឯង ដោយឆន្ទៈឥទ្ធិពល« la volonté de puissance » ។ តាម នីតឆ៍ សភាវគតិចាក់ឫសយ៉ាងជ្រៅទៅក្នុងជីវិតសត្វ សភាវៈនេះជាថាមពលសម្រាប់ប្តូរភាវៈរបស់សត្វមិនចេះចប់ជាឃ្លាំងនៃកម្លាំងនិមិត្តកម្ម(création) និងលំនឹកទាំងឡាយ «toute inspiration»។ វគតិមនុស្ស ដែល នីតឆ៍ យល់នោះ មិនមែនជាសភាវគតិម៉េកានិករបស់សត្វដែលកំណត់សត្វឲ្យរស់ក្នុងអតីតកាលឡើយ។មនុស្សគ្មានអតីតកាលទេមានតែអនាគតអ្វីដែលជាតម្លៃសម្រាប់មនុស្ស គឺអ្វីដែលមិនទាន់មាន ហើយដែលគេនឹងធ្វើអ្វីនោះស្រេចតែនឹងក្បាលចិត្តរបស់គេ។

លោក ប៊ែរសុន (Bergson) យល់ថា ធម្មជាតិជីវិតមានអត្តៈពីរៈ អត្តៈសើខាងក្រៅ (le moi superficiel) និងអត្តៈខាងក្នុង (le moi profond)។ អត្តៈសើខាងក្រៅនេះ ជាលក្ខណៈខាងក្រៅរបស់មនុស្ស ដែលទទួលឥទ្ធិពលគ្រប់បែបយ៉ាងពីសង្គម មានចរិត បុគ្គលិកលក្ខណៈចិត្ត-សង្គម(personna lité psycho-sociale) ជាដើម ប្រសិនបើសរុបន័យទៅ គឺលក្ខណៈខាងក្រៅដែលយើងអាចយល់បាន ដែលចិត្តវិទ្យាសង្គមវិទ្យា អាចសិក្សាបាន។ អត្តៈខាងក្រៅនេះមានភាពសំបូរហើយគ្មានឯកភាព គេអាចប្រៀបវាទៅនឹងស្លឹកឈើយ៉ាងច្រើនដែលអណ្តែតលើទឹកត្រពាំងមួយផ្ទុយទៅវិញអត្តៈខាងក្នុងដែលជាកត្តាសំខាន់នៃសកម្មភាពមនុស្ស មានភាពច្របូកច្របល់ មានចលនាគ្មានឈប់ឈរ រកថាយ៉ាងដូចម្តេចក៏មិនត្រូវ មនុស្សខ្វះភាសាបកស្រាយភាពពិសេសរបស់វា និងជីវិតវាបាន។

មិនតែលោក ប៊ែរសុន ទេដែលនិយាយពីរឿងនេះ តែលោក គូស្តាវប៊ីឡូត៍ក៏គាត់បានពោលប្រហែលនឹង ប៊ែរសុន ដែរ : « Le moi profond est relativement fragmentaire ... C ´ est là qu ´ on rencontre, au lieu de l ´ harmonie et du consensus, les incohérences et les contradictions, obscures batailles de la vie intérieures .»។ អត្តៈខាងក្នុងនេះស្ទុះចេញពីពន្ធនាគារអតីតកាលជានិច្ច ដើម្បីការសម្រេចនូវតម្លៃនិងឧត្តមគតិថ្មី ពួកវរជនទាំងឡាយមានអត្តៈខាងក្នុងនេះខ្លាំងក្លាសម្បើមណាស់ គាត់ធ្វើឲ្យជញ្ជាំងនៃគំនិត ចាស់គំរិលនៃរបស់សង្គមប្រពៃណី បាក់បែករបើករបាញខ្ទេចខ្ទីអស់ ឧត្តមគតិគាត់ហាក់ខ្ពស់ត្រដែតផុតគេផុតឯង ឧត្តមគតិដែលប្រវត្តិសាស្ត្រលោកទុកជាវត្ថុថ្មីហើយមានតម្លៃ ឧត្តមគតិគាត់ក្លាយជាគំរូសម្រាប់ជនដទៃ មានព្រះពុទ្ធ ព្រះយេស៊ូ ព្រះអាឡាហ៍ មហាត្មគន្ធី ជាដើម។ តាមលោក សាត្រ (Sartre) លោកនៅក្រៅខ្លួនយើងនេះ ព្រមទាំងកាយយើងជាភាវៈ (En-soi)។ មនុស្សរបស់ សាត្រ មិនមែនកាយទេ តែវិញ្ញាណ (la conscience) ដែលគាត់ហៅថា pour-soi។ Pour-soi នេះមានអនុភាពណាស់ វាអាចដកខ្លួនវាវាចេញពីកាយ ចេញពីភាវៈ(En-soi ឬ Etre) ហើយ យកភាវៈនេះមកចោទជាបញ្ហារិះគន់ឡើងវិញ ឬទាត់ភាវៈនេះចោលទុក ជាសូន្យតែម្តងក៏បាន « Le propre du pour-soi, c ´est de s ´ interroger sur l ´ être , de mettre celui-cien question par le doute criyique ou sceptique, donc de se mettre lui-même en dehors de l ´ être , de s´ arracher à lui , de le néantiser.»។ មនុស្សមានសេរីភាពបរិបូណ៌ដោយភវៈ ឬជីវិតទាំងដុលកើតមកមុនសារជាតិគ្មាន «សភាពមនុស្ស» ដែលត្រូវឆ្លាក់ហើយស្រេច ឬនៅនឹងថ្កល់នេះទេ មនុស្សគឺជាអ្វី

ដែលវាកំពុងឆ្ពោះទៅរក តើមនុស្សកកើតពីអ្វី?(l ´ homme est ce qu ´ il se fait)។ ពិតមែនហើយថា មនុស្សជាអតីតកាលមួយដែរតែស្រេចតែខ្លួនគេទេដែលទទួលឬច្រានចោលអតីតកាលនេះ។ពិតមែន មនុស្ស មើលឃើញខ្លួនគេស្ថិតនៅក្នុង«ស្ថានភាព» ណាមួយ ប៉ុន្តែស្រេចតែនឹងគេទទួលខុសត្រូវពីស្ថានភាពនោះ។ កម្មករគ្មានបានជ្រើសយកភាពកម្មករទេ តែបើគេជាកម្មករវិញស្រេចតែនឹងគេព្រមទទួល ឬច្រាន ចេញនូវលក្ខខណ្ឌវណ្ណៈអធន។ មនុស្សនៃប្រទេសបរាជ័យណាមួយ មិនបានជ្រើសយកបរាជ័យទេ តែស្រេច តែនឹងគេសុខចិត្តទទួល ឬស្ទុះចេញពីទាសភាព។ ក្នុងន័យនេះមិនមែនដោយហេតុខ្ញុំមានសេរីភាព ទើបខ្ញុំគេចផុតពីការកំណត់នៃបុព្វហេតុខាងក្រៅទេ តែផ្ទុយទៅវិញគឺរចនាសម្ព័ន្ធនៃបុព្វហេតុខាងក្រៅនោះតែម្តង ដែល ជាលក្ខខណ្ឌសេរីភាពរបស់ខ្ញុំ។ មនុស្សមានសេរីភាពរបស់គេពេញលេញ គ្មានអ្វីមកកំណត់មនុស្សបានទេ «L ´homme est condamné à être libre» ។ លោក កាមុស (Camus) បានសង្កត់បន្ថែមទៀតថាការបះប្រឆាំងជា «ធម្មជាតិមនុស្សទូទៅ ដើម្បីផុតចេញពីការជិះជាន់» ក្នុងន័យនេះ បើអតីតកាលជាគុក មនុស្សជាជនមានទោសដែលមិនព្រមរស់ក្នុងគុក ហើយរកមធ្យោបាយដោះខ្លួនពីគុកជានិច្ច។

ទស្សនវិជ្ជាអវសាននិយម (immanentisme) យល់ថា លោកយើងនេះតែងវិវត្តទៅរកភាពប្រណីត។ ប្រណីតភាពនឹងកើតឡើងនៅទីបំផុតនៃលោក ប្រណីតភាពមនុស្សនឹងត្រូវកើតឡើងនៅទីបំផុតនៃប្រវត្តិមនុស្សជាតិ។បរមត្ថវិជ្ជា (métaphysique) ពួកនេះបង្ហាញថា នៅក្នុងលោកយើងនេះ នៅក្នុងខ្លួនមនុស្សយើងនេះមានសារធាតុបង្កប់ « Virtualité latente » ដែលនឹងរីកក្លាយជាការពិតដ៏ប្រណីតនៅទីបំផុតប្រវត្តិ លោក។ សារធាតុបង្កប់នេះសំបូរនូវសព្វធាតុទាំងឡាយឥតទីបញ្ចប់អំណាចឥតព្រំដែននៃពុទ្ធិនៃដំណូរថ្មី (renouvelle ment) នៃសមត្ថិកម្ម នៃសកម្មភាព។ ដូចនេះ មនុស្សមានធាតុសំខាន់ម្យ៉ាងអាចនៅទីអវសានទៅដល់ភាពប្រណីតនេះបាន។ ធាតុសំខាន់នោះ លោក ស្ពីណូហ្សា ហៅថាធម្មជាតិ (Nature) លោក អេហ្គែល ហៅថា ចិត្ត (Esprit) លោក ប៊ែរសុន ហៅថា សន្ទុះជីវិត (Elan-Vital) លោក ប្រ៊ែនស្វិក ហៅថា វិញ្ញាណ (Con science)។

តាមអស្ថិវាទខាងលើ ថ្វីត្បិតតែសារធាតុបង្កប់សារធាតុមានមកស្រាប់ តែវាជាអាថ៌កំបាំងនៅក្រៅអតីតភាព។ អតីតភាពគ្រាន់ជាដំណាក់នៃទំហឹងវឌ្ឍនៈរបស់វា ដែលពុទ្ធិប្រធានយកជាឈ្នាន់ហក់ទៅរកឧត្តមភាព « L ´ homme est Dieu qui se fait »។

មនុស្សវិទ្យាចាត់ទុកសភាពមនុស្សបច្ចុប្បន្នជាវិបាកអតីតកាលហើយសភាពនេះកំណត់មនុស្សឲ្យនៅក្នុងលានអំណាចរបស់វា។ទស្សនវិទូមិនទាត់ចោលអតីតកាលទេតែស្ថានភាពពុំអាចកំណត់ឥរិយាបថមនុស្សបានឡើយ មនុស្សអាចសម្រេចវាសនាខ្លួនដោយកម្លាំងវិចារណញ្ញាណ។ គំហើញមនុស្សវិទ្យាគ្រាន់តែជាសច្ចៈមួយក្នុងវង្វង់ទស្សនសច្ចៈ (Vérité philosophique) ប៉ុណ្ណោះ។ ការដែលមនុស្សវិទ្យាជួបប្រទះនឹងបញ្ហាសេរីភាពមនុស្ស ដែលជាជ្រលងជ្រោះជ្រៅមិនអាចឆ្លងរួចនេះ ជាសក្ខីកម្មនៃបរាជ័យរបស់ខ្លួនក្នុងបំណងយកពុទ្ធិប្រធានជាវត្ថុសិក្សាដូចរូបធាតុទាំងឡាយក្នុងលោក។

# II- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

## ១- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទបញ្ញត្តិបច្ចេកទេសសំណង់ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទបញ្ញត្តិបច្ចេកទេសសំណង់

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទបញ្ញត្តិបច្ចេកទេសសំណង់ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិបទបញ្ញត្តិបច្ចេកទេសសំណង់ ត្រូវបានរៀបចំឡើងដោយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី ស្នើសុំដាក់ប្រជុំកម្រិតបច្ចេកទេសជាមួយតំណាងក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទៅតាមនីតិវិធីជាធរមាន កាលពីដើមខែ មីនា ឆ្នាំ២០២១។

យោងតាមសំណើដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងចំណាររបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ឆាយលី** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមការងារទី១ របស់ ក.ស.វ. ដឹកនាំដោយឯកឧត្តម **លី គឹមសុខ** អនុប្រធាន ក.ស.វ. និងជាប្រធានក្រុម បានធ្វើការសិក្សាផ្តល់យោបល់លើសេចក្តីព្រាង ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី កាលពីខែឧសភាកន្លងទៅ។

ជាបន្តសេចក្តីព្រាងអនុក្រឹត្យទាំងពីរត្រូវបានលើកយកមកពិនិត្យនិងពិភាក្សានៅក្នុងកិច្ចប្រជុំបច្ចេកទេសចង្អៀតមួយដឹកនាំដោយ ឯកឧត្តម **លី គឹមសុខ** អនុប្រធាន ក.ស.វ. ប្រធានក្រុមការងារទី១ និង ឯកឧត្តម **ស៊ា ម៉ៅ** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់។ កិច្ចប្រជុំនេះធ្វើឡើងកាលពីថ្ងៃទី១៥ ខែកញ្ញា ហើយបញ្ចប់នៅព្រឹកនាថ្ងៃបន្ទាប់ តាមប្រព័ន្ធអនឡាញ(ZOOM) ជាមួយឯកឧត្តម **ថេង ចន្ទសង្វារ** តំណាងក្រសួងដែនដីនគរូបនីយកម្មនិងសំណង់និងសហការីនិងមានការចូលរួមពីសមាជិកនិងមន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់។

ជារួម សេចក្តីព្រាងអនុក្រឹត្យទាំងពីរត្រូវបានរៀបចំឡើងទៅតាមការចង្អុលបង្ហាញរបស់មាត្រា១១ នៃច្បាប់ស្តីពីសំណង់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩និងស្របតាមគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣។

**១.សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទបញ្ញត្តិបច្ចេកទេសសំណង់(ក.ជ.ប.ស.)**

អង្គប្រជុំបច្ចេកទេសចង្អៀត បានលើកយកសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក.ជ.ប.ស. មកពិភាក្សាមុន។ អង្គប្រជុំបានឯកភាពលើចំណងជើងសេចក្តីព្រាង និងលើមូលបទ ព្រោះស្របទៅតាមគោលការណ៍ណែនាំ។

ដោយឡែកចំពោះមាត្រា១ អង្គប្រជុំបានធ្វើការកែសម្រួលឱ្យខ្លី ឱ្យមានសង្គតិភាពជាមួយសេចក្តីព្រាងអនុក្រឹត្យទី២ ដែលរៀបចំដោយក្រុមការងារតែមួយ។ នៅក្នុងជំពូកទី២ ការពិភាក្សាបានផ្តោតទៅលើពាក្យ "អនុប្រធានអចិន្ត្រៃយ៍"។ បន្ទាប់ពីការពិភាក្សាគ្នា អង្គប្រជុំបានឯកភាពប្តូរពាក្យ "អចិន្ត្រៃយ៍" ទៅជា "ប្រចាំការ" វិញ ហើយបន្ថែមរដ្ឋលេខាធិការទីស្តីគណៈរដ្ឋមន្ត្រី ១ រូបទៀត ជាសមាជិករបស់ ក.ជ.ប.ស.។

ក្រៅពីនេះមានការប្តូរពាក្យ"នាយកមន្ទីរ"ទៅជា"អគ្គនាយកមន្ទីរ"ត្រង់ចំណុចលេខ២១និងកែសម្រួលពាក្យ"សមាជិក"ក្នុងកថាខណ្ឌបន្ទាប់ចុងក្រោយទៅជា"សមាសភាព"ពាក្យ"កំណត់"ក្នុងកថាខណ្ឌចុងក្រោយបង្អស់ទៅជា "តែងតាំង" វិញ។

ចំពោះមាត្រា៣ ដែលចែងអំពីតួនាទី និងភារកិច្ចរបស់ ក.ជ.ប.ស. មានការបន្ថែមពាក្យ "រៀបចំនិង" នៅដើមគំនូសទី១ និងពាក្យ"តាមដានការអនុវត្តនិង"នៅដើមគំនូសទី៣។ក្នុងមាត្រា៣នេះក៏មានការពិភាក្សាគ្នាលើពាក្យ "សហប្រតិបត្តិការ" ដែរ។ អង្គប្រជុំបានពិចារណាប្រៀបធៀបជាមួយនឹងពាក្យ "សហការ" ។ នៅចុងបញ្ចប់អង្គប្រជុំបានឯកភាពរក្សាទុកពាក្យ "សហប្រតិបត្តិការ" គំនូសទី៥ ឱ្យនៅដដែល។

ការបន្ថែមសញ្ញា "ៗ" នៅពីក្រោយពាក្យ "ផ្សេង" គំនូសចុងក្រោយនៃមាត្រាទី៣ ( "-អនុវត្តភារកិច្ចផ្សេងៗទៀត..." ក៏ត្រូវបានលើកផងដែរ ដើម្បីធ្វើឱ្យខ្លឹមសារនៃគំនូសទី៥នេះមានន័យច្បាស់លាស់។

ឃ្លាប្រយោគក្នុងមាត្រា៤ត្រូវបានកែសម្រួលឱ្យខ្លីដោយលុបពាក្យ "ដែលប្រធាន ក.ជ.ប.ស." ក្នុងឃ្លាទី២ បន្ទាប់ពីពាក្យ "ក្នុងករណី"។

ចំពោះកថាខណ្ឌទី៣ និងទី៤ នៃមាត្រា៦ ដែលចែងអំពីការតែងតាំងអគ្គលេខាធិការ និងអគ្គលេខាធិការរង ការបំពេញភារកិច្ចរបស់អគ្គលេខាធិការរង ត្រូវបានអង្គប្រជុំឯកភាពដកចេញ ទុកសរសេរនៅក្នុងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក.ជ.ប.ស.វិញ។

ដើម្បីឱ្យស្រួលស្តាប់ ល្បះទី១ នៃមាត្រា៧ ក៏ត្រូវបានកែសម្រួល ដោយកែពាក្យ "ដើម្បីបំពេញការងាររបស់ខ្លួន" ទៅជា "ក្នុងការបំពេញការងារ" ដោយខ្លីបែបនេះ។

ចំពោះខ្លឹមសារមាត្រា៨ជំពូកទី៤ប្រភពធនធានអង្គប្រជុំបានឯកភាពឱ្យយកតាមគំរូស្តង់ដារដាក់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំពោះរូបមន្តបញ្ចប់នៃសេចក្តីព្រាង អង្គប្រជុំបានពិនិត្យផ្តល់ការឯកភាពទៅតាមការកែសម្រួលរបស់ក្រុមការងារក្រុមប្រឹក្សាអ្នកច្បាប់។

**២.សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក.ជ.ប.ស**

មាត្រា១១ នៃច្បាប់ស្តីពីសំណង់ចែងថា "ក.ជ.ប.ស. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ" ហើយមាត្រា៦ នៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក.ជ.ប.ស. ចែងថា "ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក.ជ.ប.ស. ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក"។ គឺតាម

ការចង្អុលបង្ហាញនេះហើយដែលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក.ជ.ប.ស. ត្រូវបានតាក់តែងឡើង។

ដោយសេចក្តីព្រាងអនុក្រឹត្យជាការកំណត់ការរៀបចំរចនាសម្ព័ន្ធ និងការគ្រប់គ្រងដឹកនាំ អង្គប្រជុំបានឯកភាពតាមការស្នើរបស់ក្រុមការងារក្រុមប្រឹក្សាអ្នកច្បាប់ បញ្ចូលអនុក្រឹត្យចំនួន២បន្ថែមទៀតក្នុងមូលបទ គឺៈ

១-អនុក្រឹត្យលេខ៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

២-អនុក្រឹត្យលេខ១១៤អនក្រ.បកចុះថ្ងៃទី៧ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ចំពោះការប្រើប្រាស់ត្រារបស់អគ្គលេខាធិការដ្ឋានដោយឡែកពី ក.ជ.ប.ស. អង្គប្រជុំបានពិភាក្សាគ្នារួចហើយក្នុងរបៀបវារៈទី១ហើយបានឯកភាពរក្សាទុកការអនុវត្តបែបនេះឱ្យនៅដដែលតាមការស្នើសុំរបស់ក្រសួងសាមី។

យោងទៅតាមការអនុវត្តថ្មី អង្គប្រជុំបានឯកភាពកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋាន ពីផ្នែកទៅជានាយកដ្ឋាន ពីលេខាធិការដ្ឋានទៅនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុនិងពីប្រធានលេខាធិការដ្ឋានអនុប្រធានលេខាធិការដ្ឋានប្រធានផ្នែកអនុប្រធានផ្នែក ទៅជាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋានវិញ។

ចំពោះការរៀបចំរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននេះក្រសួងសាមីបានឯកភាពថានឹងធ្វើការពិភាក្សាឆ្លងយោបល់ក្រសួងមុខងារសាធារណៈ ក្នុងពេលជាបន្ទាន់។

ចំពោះរូបមន្តបញ្ចប់នៃសេចក្តីព្រាង ក្រុមការងារក្រុមប្រឹក្សាអ្នកច្បាប់បានតាក់តែង កែសម្រួលជាថ្មីស្របតាមគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យទាំងពីរត្រូវបានបញ្ចប់ ដោយធ្វើសេចក្តីសន្និដ្ឋានថា គួរដាក់សេចក្តីព្រាងទាំងពីរនេះក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀតជាបន្តតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការចូលរួមពីសមាសភាពរបស់ ក.ជ.ប.ស.។

*ដោយ សួង លាងហៃ - (ក.ស.វ. - ក្រុម ១)*

# ២- សេចក្តីព្រាងអនុក្រឹត្យនៃការគ្រប់គ្រងការប្រមូលហៅម្ហូបអាហារត្រឡប់មកវិញ

អនុក្រឹត្យនៃការគ្រប់គ្រងការប្រមូលហៅម្ហូបអាហារត្រឡប់មកវិញ ជាសេចក្តីព្រាងអនុក្រឹត្យរៀបចំឡើងដោយក្រសួងពាណិជ្ជកម្ម កំណត់ពីយន្តការ និងសមត្ថកិច្ចគ្រប់គ្រងការប្រមូលត្រឡប់មកវិញនូវម្ហូបអាហារដែលគ្មានសុវត្ថិភាព ឬដែលមិនអនុលោមតាមបទបញ្ញត្តិបច្ចេកទេស ដើម្បីការពារដល់សុខភាព និងផលប្រយោជន៍អ្នកប្រើប្រាស់ ។ ម្ហូបអាហារដែលគ្មានសុវត្ថិភាពឬដែលមិនអនុលោមតាមបទបញ្ញត្តិបច្ចេកទេស សំដៅលើសារធាតុណាមួយទោះបីជាត្រូវកែច្នៃទាំងស្រុងឬពាក់កណ្តាលកែច្នៃឬមិនទាន់កែច្នៃដែលមានបំណងសម្រាប់ការបរិភោគរបស់មនុស្ស និងរួមទាំងភេសជ្ជៈ ស្ករកៅស៊ូ និងសារធាតុណាមួយដែលត្រូវ បានប្រើប្រាស់នៅក្នុងផលិតកម្ម ការរៀបចំ ឬការធ្វើប្រព្រឹត្តកម្មនៃម្ហូបអាហារ ក៏ប៉ុន្តែមិនរួមបញ្ចូលនូវគ្រឿងសំអាង ឬថ្នាំជក់ ឬសារធាតុទាំងឡាយណាដែលប្រើសម្រាប់ឱសថ ។

អនុក្រឹត្យនៃការគ្រប់គ្រងការប្រមូលហៅម្ហូបអាហារត្រឡប់មកវិញ មាន ៦ជំពូកនិង១៨មាត្រា ក្រសួងពាណិជ្ជកម្មជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងការប្រមូលត្រឡប់មកវិញនូវម្ហូបអាហារដែលគ្មានសុវត្ថិភាព ឬដែលមិនអនុលោមតាមបទបញ្ញត្តិបច្ចេកទេស ដោយមានអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង សរសេរកាត់ថា ក.ប.ប. ជាសេនាធិការ ។

សេចក្តីព្រៀងអនុក្រឹត្យនេះកំណត់ផងដែរនូវកាតព្វកិច្ចរាល់បុគ្គលធ្វើធុរៈកិច្ចម្ហូបអាហារដែលគ្មានសុវត្ថិភាព ឬដែលមិនអនុលោមតាមបទបញ្ញត្តិ បច្ចេកទេស តាមលក្ខខណ្ឌតម្រូវដូចជា រៀបចំប្រព័ន្ធអង្កេតដាន បិទស្លាក និងកំណត់អត្តសញ្ញាណម្ហូបអាហារធ្វើចរាចរលើទីផ្សារជាដើម។រីឯទម្រង់បែបបទនៃការប្រមូលហៅម្ហូបអាហារដែលគ្មានសុវត្ថិភាព ឬដែលមិនអនុលោមតាមបទបញ្ញត្តិបច្ចេកទេស ត្រឡប់មកវិញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

នីតិវិធីចំពោះការប្រមូលហៅម្ហូបអាហារដែលគ្មានសុវត្ថិភាព ឬដែលមិនអនុលោមតាមបទបញ្ញត្តិបច្ចេកទេសត្រឡប់មកវិញបន្ទាប់ពីទទួលបានការជូនដំណឹងពីក្រសួងពាណិជ្ជកម្មស្ថាប័នមានសមត្ថកិច្ចបុគ្គលធ្វើធុរៈកិច្ចម្ហូបអាហារ ត្រូវចាប់ផ្តើមអនុវត្តការប្រមូលម្ហូបអាហារត្រឡប់មកវិញជាបន្ទាន់ រួមមានការផ្អាកផលិតកម្ម ការនាំចេញ ការចែកចាយ ឬផ្អាកការធ្វើធុរៈកិច្ចម្ហូបអាហារដែលគ្មានសុវត្ថិភាព ឬដែលមិនអនុលោមតាមបទបញ្ញត្តិបច្ចេកទេស ហើយត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងពាណិជ្ជកម្ម និងក្រសួង ស្ថាប័នមានសមត្ថកិច្ច។

អនុក្រឹត្យនៃការគ្រប់គ្រងការប្រមូលហៅម្ហូបអាហារត្រឡប់មកវិញ ក៏កំណត់ផងដែរនូវទណ្ឌកម្ម ឬការផាកពិន័យអន្តរការណ៍ចំពោះបុគ្គលធ្វើធុរៈកិច្ចម្ហូបអាហារដែលគ្មានសុវត្ថិភាព ឬដែលមិនអនុលោមតាមបទបញ្ញត្តិបច្ចេកទេស ដូចជាការព្រមាន ការបង់ប្រាក់ផាកពិន័យអន្តរការណ៍រំលត់បណ្តឹងជាដើម។

*ដោយ ទេស អែតដា - (ក.ស.វ. - ក្រុម ២)*

## ៣- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាបានចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា តាមព្រះរាជក្រមលេខ នស/រកម/០១០៧/00៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧។ ជាមួយនេះ សេចក្តីថ្លែងការណ៍ស្តីពីការប្រឆាំងដូប៉ាក្នុងវិស័យកីឡា ត្រូវបានអនុម័តដោយអង្គការយូណេស្កូ និងតម្រូវឱ្យប្រទេសហត្ថលេខី ឯកភាពលើការប្រយុទ្ធប្រឆាំងដូប៉ាក្នុងវិស័យកីឡា ព្រមទាំងបង្កើតទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ទីភ្នាក់ងារប្រឆាំងដូប៉ាតំបន់ និងទីភ្នាក់ងារប្រឆាំងដូប៉ាក្នុងប្រទេសនីមួយៗ។

ឆ្លើយតបនឹងសេចក្តីថ្លែងការណ៍នេះ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា ដើម្បីបំពេញកាតព្វកិច្ចរបស់កម្ពុជាជារដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិនេះ និងដើម្បីបានអនុវត្តត្រឹមត្រូវតាមស្តង់ដានៃវិស័យកីឡា ទាំងកម្រិតតំបន់និងពិភពលោក។ អនុក្រឹត្យនេះនឹងរួមចំណែកអនុវត្តនូវគោលការណ៍ចូលរួមដោយស្មើភាព ធានាបាននូវយុត្តិធម៌និងដើម្បីការពារសុខភាពកីឡាករដែលចូលរួមក្នុងការប្រកួតកីឡា ក្នុងកម្រិតជាតិនិងអន្តរជាតិ ក្រោមការគ្រប់គ្រងរបស់ស្ថាប័នកីឡា។

សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេស តាមប្រព័ន្ធអនឡាញ ហើយរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៣និង២៤ ខែសីហា ឆ្នាំ២០២១។

ក្នុងដំណើរកិច្ចប្រជុំនេះតំណាងក្រសួងសាមីបានលើកជូនកិច្ចប្រជុំជ្រាបនូវបញ្ញត្តិថ្មីសំខាន់២ដែលប្រើនៅក្នុងសេចក្តីព្រាងនេះ៖

-ដូប៉ា សំដៅដល់សារធាតុឬវិធីផ្សេងៗដែលកីឡាករ កីឡាការិនីប្រើប្រាស់ ដើម្បីបង្កើនគុណផលក្នុងការប្រកួត ហើយដែលត្រូវបានច្បាប់ហាមឃាត់(អង់គ្លេស-doping)។

-អត្តពលិកសំដៅដល់បុគ្គលទាំងឡាយដែលចូលរួមការប្រកួតកីឡាក្នុងកម្រិតជាតិនិងអន្តរជាតិក្រោមការគ្រប់គ្រងរបស់ស្ថាប័នកីឡា អង់គ្លេស-athlete (និយមន័យក្នុងអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា)។

កិច្ចប្រជុំបានយកចិត្តទុកដាក់ពិភាក្សាលើការរៀបចំសមាសភាពគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា សមាសភាពនិងមុខងារភារកិច្ចអនុគណៈកម្មាធិការជំនាញទាំងពីររបស់គណៈកម្មាធិការគឺអនុគណៈកម្មាធិការដោះស្រាយវិវាទដូប៉ានិងអនុគណៈកម្មាធិការលើកលែងថ្នាំព្យាបាល។ដើម្បីបំពេញតួនាទីនិងភារកិច្ចដ៏សំខាន់របស់គណៈកម្មាធិការដែលអនុលោមតាមអង្គការតំបន់អាស៊ីអាគ្នេយ៍ប្រឆាំងដូប៉ា(SEARADO) ទីភ្នាក់ងារពិភពលោកប្រឆាំងដូប៉ា(WADA)និងបទពិសោធប្រទេសនានាឱ្យទទួលបានលទ្ធផលល្អសមាសភាពត្រូវបានរៀបចំឡើងមកពីបណ្តាក្រសួង ស្ថាប័នជាច្រើន មានក្រសួងគ្រប់គ្រងឬអភិវឌ្ឍវិស័យកីឡា ក្រសួងពាក់ព័ន្ធនឹងការត្រួតពិនិត្យលើការនាំចូលទំនិញក្រសួងពាក់ព័ន្ធនឹងដោះស្រាយវិវាទក្រសួងពាក់ព័ន្ធផ្សេងៗទៀតនិងស្ថាប័នកីឡា(គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និងគណៈកម្មាធិការជាតិ

ស្ញៀស្សាល់អូឡាំពិកកម្ពុជា)។

អនុគណៈកម្មាធិការលើកលែងថ្នាំព្យាបាល មានតំណាងក្រសួងសុខាភិបាលជាប្រធាន។ ភារកិច្ចចម្បងរបស់អនុគណៈកម្មាធិការនេះ គឺពិនិត្យនិងវាយតម្លៃប្រភេទជំងឺនិងថ្នាំដែលអត្តពលិកស្នើសុំប្រើសម្រាប់ព្យាបាល និងធ្វើការសម្រេចលើការស្នើសុំ ដូចជាការលើកលែងឱ្យប្រើថ្នាំបានតាមសំណើ។

អនុគណៈកម្មាធិការដោះស្រាយវិវាទដូប៉ាត្រូវជាស្ថាប័នឯករាជ្យ ហើយមានតួនាទីសំខាន់ណាស់ ទាំងក្នុងប្រទេសទាំងក្នុងទំនាក់ទំនងជាមួយអង្គការនិងទីភ្នាក់ងារតំបន់ឬអន្តរជាតិប្រឆាំងដូប៉ាព្រោះករណីប្រើប្រាស់ដូប៉ានេះតែងកើតមានឡើងចំពោះអត្តពលិក បង្កើតជាដំណោះស្រាយនិងបណ្តឹងស្មុគស្មាញ។ មេធាវីដែលជាប្រធានអនុគណៈកម្មាធិការនេះ ត្រូវមានការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងការប្រឆាំងដូប៉ា ហើយត្រូវតែមានការទទួលស្គាល់ដោយអង្គការឬទីភ្នាក់ងារសមត្ថកិច្ចប្រឆាំងដូប៉ា។

កិច្ចប្រជុំជំនាញបច្ចេកទេសនេះ ត្រូវបានដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ឆយ អូន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងឯកឧត្តម **ស៊ា ម៉ៅ** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធាន មានការអញ្ជើញចូលរួមពីសមាជិកនៃក្រុមប្រឹក្សាទាំងពីរ ឯកឧត្តម **អ៊ុន ទីរៈជាតិ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី តំណាងក្រសួងសាមីមានឯកឧត្តម**សុខ សប្បាយណារ** អនុរដ្ឋលេខាធិការនិងមន្ត្រីជំនាញជាអ្នកការពារសេចក្តីព្រាង ព្រមទាំងមន្ត្រីជំនាញអង្គភាពពាក់ព័ន្ធនៃទីស្តីការគណៈរដ្ឋមន្ត្រី។

*ដោយ ឆយ អូន - (ក.ស.វ. - ក្រុម ៣)*

**<u>គំនិតគួរពិចារណា</u>**

« ក្នុងការធ្វើពលិកម្ម១ ក្នុងការធ្វើវិវាហៈ១ ក្នុងការអន្តរាយ១
ក្នុងការកំចាត់បង់នូវសត្រូវ១ ក្នុងការតំកើងយស១ ក្នុងការសង្គ្រោះមិត្ត១
ក្នុងភរិយាជាទីស្រឡាញ់១ ក្នុងផៅពង្សដែលក្រីក្រ១
វត្ថុទាំង៨ប្រការនេះ លោកមិនហៅថាខ្ជះខ្ជាយទ្រព្យទេ។ »

លោកនីតិបករណ៍ - ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

## ១- ប្រទេសចិនៈ គូប្រជែងដែលមានឥទ្ធិពលនយោបាយនិងថាមពលយោធាគ្រប់គ្រាន់ទប់ទល់ជាមួយនឹងនយោបាយវៀចវេររបស់សហរដ្ឋអាមេរិក

អ្នកដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតប្រចាំនៅប្រទេសចិន របស់លោកប្រធានាធិបតីសហរដ្ឋ-អាមេរិក Joe Biden គឺលោក Nicholas Burns ។

លោក Burns បានប្រកាន់ខ្ជាប់នូវទំនាក់ទំនងដ៏តឹងតែងជាមួយនឹងប្រទេសចិននៅក្នុងសវនាការផ្តល់សេចក្តីទុកចិត្តនៅចំពោះមុខគណកម្មាធិការទំនាក់ទំនងព្រឹទ្ធសភា (Senate Foreign Relations Committee) ដោយនិយាយចោទប្រកាន់និងបរិហារកិច្ចការផ្ទៃក្នុងរបស់ប្រទេសចិន។

លោក Burns បានហៅប្រទេសចិនថាជា "គូប្រជែងដ៏គ្រោះថ្នាក់បំផុតរបស់សហរដ្ឋអាមេរិក" និងបាននិយាយត្មះតិះដៀលអតីតកាលអំពីទីក្រុងប៉េកាំងដោយបានបន្ថែមថា "ទីក្រុងវ៉ាស៊ីនតោនគួរតែធ្វើការជាមួយសម្ព័ន្ធមិត្តនៅអឺរ៉ុប និងកន្លែងផ្សេងទៀតដើម្បីកសាងឥទ្ធិពលសេដ្ឋកិច្ចប្រឆាំងនិងប្រទេសចិន" ។

អ្នកតស៊ូមតិផ្នែកសិទ្ធិមនុស្ស និងរដ្ឋាភិបាលសហរដ្ឋអាមេរិកក៏បានហៅការប្រព្រឹត្តរបស់ចិនទៅលើជនជាតិ Uyghur នៅក្នុងតំបន់ Xinjiang ថាជាអំពើប្រល័យពូជសាសន៍ - ដែលជាលក្ខណៈមួយរដ្ឋាភិបាលចិនបានបដិសេធ។

លោក Burns បាននិយាយថា "អំពើប្រល័យពូជសាសន៍របស់ PRC នៅទីក្រុង Xinjiang ការរំលោភបំពាននៅ Tibet ការបំផ្លាញស្វ័យភាពនិងសេរីភាព Hong Kong និងការគំរាមកំហែងលើកោះ Taiwan គឺអយុត្តិធម៌ ហើយត្រូវតែបញ្ឈប់" ។

លោក Burns ដែលមានអាយុ 65 ឆ្នាំជាអ្នកការទូតអាជីព និងជាអតីតឯកអគ្គរដ្ឋទូតប្រចាំអង្គការ NATOក៏បាននិយាយថាទីក្រុងវ៉ាស៊ីនតោនគឺត្រឹមត្រូវក្នុងការប្រកាន់ខ្ជាប់នូវគោលនយោបាយ"ចិនតែមួយ[One China policy]" របស់ខ្លួនលើកោះ Taiwan ក៏ប៉ុន្តែសហរដ្ឋអាមេរិកគប្បីរក្សាសិទ្ធិក្នុងការប្រឆាំងនឹងសកម្មភាពរបស់ទីក្រុងប៉េកាំងដែលនាំឱ្យប៉ះពាល់ដល់ស្ថានភាពស្ថិរភាពបច្ចុប្បន្ន។

អ្នកតាក់តែងច្បាប់ [Law-makers] មួយចំនួនរួមទាំងសមាជិកគណបក្សប្រជាធិបតេយ្យរបស់លោកប្រធានាធិបតី Joe Biden បានអំពាវនាវឱ្យទីក្រុងវ៉ាស៊ីនតោនពិនិត្យឡើងវិញនូវគោលនយោបាយដែលមានអាយុកាលរាប់ទសវត្សរ៍មកហើយដែលមិនប្រកាន់ជំហរណាមួយលើអធិបតេយ្យភាពរបស់ Taiwan ។

លោក Burns បាននិយាយថាការគំរាមកំហែងផ្នែកយោធារបស់ចិនចំពោះកោះ Taiwan កំពុងកើនឡើង ប៉ុន្តែការរក្សាគោលនយោបាយចិនតែមួយ ( oneChinapolicy ) គឺជាវិធីដ៏ឆ្លាតវៃនិងមានប្រសិទ្ធភាពបំផុតដើម្បីរារាំងចិនពីការប្រើកម្លាំងលើកោះប្រជាធិបតេយ្យដែលគ្រប់គ្រងដោយខ្លួនឯង។

លោក Burns បានប្រាប់គណៈកម្មាធិការទំនាក់ទំនងការបរទេសព្រឹទ្ធសភាថា "នេះគឺជាគោលនយោបាយដែលអាចទទួលបានជោគជ័យប្រសិនបើយើងប្រតិបត្តិវាដោយខ្ជាប់ខ្ជួននិងដោយកម្លាំងខ្លះ" ។

ទោះយ៉ាងណាលោក Burns បាននិយាយថាសភានិងស្ថាប័ននីតិប្រតិបត្តិមានសិទ្ធិ"ពង្រីកការលក់សព្វាវុធដល់ Taiwan ដែលជា "គ្រាប់ដ៏លំបាកក្នុងការបង្ក្រាប" ។

លោក Burns បានអះអាងនៅចំពោះមុខគណកម្មាធិការព្រឹទ្ធសភាថាប្រទេសចិនគឺជា"ការសាកល្បងភូមិសាស្ត្រនយោបាយធំបំផុតនៃសតវត្សរ៍ទី២១" ក្នុងអំឡុងពេលសវនាការ, ទន្ទឹមនឹងការវាយប្រហារយ៉ាងខ្លាំងក្លាគ្រប់ជ្រុងជ្រោយប្រឆាំងនឹងគោលនយោបាយក្នុងស្រុកនិងការបរទេសរបស់ចិនដោយបញ្ជាក់ដ៏តឹងរ៉ឹងបំផុត និងក្រអឺតក្រទមដ៏កម្រ ដែលឯកអគ្គរដ្ឋទូតអាមេរិកមុនៗបានធ្វើមុនពេលមកកាន់ប្រទេសចិន។

ការចោទប្រកាន់របស់ទីក្រុងវ៉ាស៊ីនតោនប្រឆាំងនឹងប្រទេសចិនក្នុងរយៈពេល ៩ ខែកន្លងមកនេះ ដូចជាការដាក់ស្លាកគោលនយោបាយរបស់ចិននៅ Xinjiang ថាជាអំពើប្រល័យពូជសាសន៍ ការប៉ះពាល់ដល់គោលការណ៍ប្រជាធិបតេយ្យនៅ Hong Kong ដោយប្រកាសថាអាមេរិកមិនអាចទុកចិត្តចិនបានទេ។

លោក Burns បានប្រកាសថាប្រទេសចិនមាន" មិត្តភក្តិតិចតួចណាស់" ។ លោកបានអំពាវនាវកុំឱ្យអាមេរិកវាយតម្លៃកម្លាំងរបស់ចិនខ្លាំងពេក និងមើលស្រាលកម្លាំងរបស់អាមេរិកដោយនិយាយថា "យើងគួរតែមានទំនុកចិត្តលើចំណុចខ្លាំងរបស់យើង - សម្ព័ន្ធមិត្តនៅក្នុងតំបន់សេដ្ឋកិច្ច និងកម្លាំងយោធា" ។

ការវាយប្រហារជាប្រព័ន្ធបែបនេះលើប្រទេសចិនមិនមែនជាអ្វីដែលឯកអគ្គរដ្ឋទូតអាមេរិកដែលចូលមកគួរធ្វើក្នុងកាលៈទេសៈធម្មតានោះទេ។ សេចក្តីថ្លែងការណ៍របស់លោក Burns បានបង្ហាញពីភាពអរិភាព ជារួមរបស់ឥស្សរជននយោបាយអាមេរិកចំពោះប្រទេសចិន។ សារនៃសវនាការគឺៈ មនុស្សម្នាក់ត្រូវតែមានភាពស្វិតស្វាញនេះ ដើម្បីធ្វើជាឯកអគ្គរដ្ឋទូតអាមេរិកប្រចាំប្រទេសចិន។

វាមិនអាចច្រានចោលបានទេដែលថាលោក Burns បានជ្រើសរើសពាក្យពិបាកៗ ដោយចេតនាដើម្បីឆ្លងកាត់សវនាការព្រឹទ្ធសភា។ វាទំនងណាស់ដែលថាបន្ទាប់ពីទៅដល់ប្រទេសចិនលោក Burns នឹងពណ៌នាថាទំនាក់ទំនងចិន-អាមេរិកមានសារៈសំខាន់ប៉ុណ្ណា។ ប៉ុន្តែពិតជាមិនចាំបាច់ទេសម្រាប់ប្រជាជនចិនដើម្បីព្យាយាមស្វែងយល់ពីអ្វីដែលនៅក្នុងចិត្តរបស់វ៉ាស៊ីនតោនពីសំដីរបស់គាត់។បន្ទាប់ពីប្រាំបួនខែ ចិនបានឃើញយ៉ាងច្បាស់ពីរបៀបដែលរដ្ឋបាលBidenនឹងដោះស្រាយជាមួយប្រទេសចិន។មិនចាំបាច់ត្រូវការឯក-អគ្គរដ្ឋទូតដែលនឹងមកទីក្រុងប៉េកាំងដើម្បីបរិហារម្តងហើយម្តងទៀតទេ។

លោក Burns គឺជាអ្នកការទូតជើងចាស់។ ជាទូទៅគាត់ត្រូវបានគេចាត់ទុកថាជាអ្នកប្រតិបត្តិគោលនយោបាយអាមេរិកចំពោះប្រទេសចិនដែលទំនងជាមិនមានលទ្ធភាពបង្កើតរបកគំហើញផ្ទាល់ខ្លួន។នៅពេលដោះស្រាយជាមួយគាត់នាពេលអនាគត,ចិនអាចមានអារម្មណ៍កាន់តែខ្លាំងក្នុងការដោះស្រាយជាមួយក្រសួងការបរទេសអាមេរិកទៅវិញទេ។

សេចក្តីថ្លែងការណ៍របស់លោកBurnsនៅក្នុងសវនាការមិនបានបង្ហាញពីសិល្បៈនៃការងារឬអារម្មណ៍នៃភាពថ្លៃថ្នូរដែលអ្នកការទូតជាធម្មតាមាននោះទេ។ ផ្ទុយទៅវិញ វាហាក់ដូចជាពេលវាលបន្តិច ដោយមានអារម្មណ៍ក្រអឺតក្រទមចំពោះប្រទេសចិន។ គេជឿជាក់ថាគាត់នឹងជួបបញ្ហាដោយចៀសមិនរួចបន្ទាប់ពីគាត់ទៅដល់ប្រទេសចិន - ភាគីចិនមិនចាំបាច់ផ្តល់ការគួរសមអ្វីដល់គាត់ទេ, លើកលែងតែសុជីវធម៌ការទូត។

ការជឿជាក់ថាដំណើរការនៃការផ្លាស់ប្តូរការយល់ដឹងនិងអាកប្បកិរិយាផ្ទាល់ខ្លួនរបស់លោក Burns ចំពោះប្រទេសចិននឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងដំណើរការផ្លាស់ប្តូររបៀបដោះស្រាយរបស់អាមេរិកជាមួយចិន។ ដំណើរការនេះនឹងមិនងាយស្រួលទេ ប៉ុន្តែការលំបាករបស់វាក៏ជាបទដ្ឋានក្នុងទំនាក់ទំនងរវាងមហា អំណាចធំៗផងដែរ។

ការកត់សម្គាល់បានឃើញថានៅក្នុងសេចក្តីថ្លែងការណ៍របស់លោក Burns មិនបានស្នើឱ្យមានវិធានការបន្ថែមថ្មីសម្រាប់សហរដ្ឋអាមេរិកក្នុងការដោះស្រាយជាមួយប្រទេសចិននោះទេ។ ដូច្នេះ ការថ្លែង អំពី ភាពតឹងតែងរបស់គាត់ហាក់ដូចជាប្រហោងបន្តិច។សំណួររបស់សមាជិកព្រឹទ្ធសភាក៏មិនត្រូវបានគេចាប់អារម្មណ៍ដែរ។ អ្វីដែលអាមេរិកខ្វះគឺមធ្យោបាយដាក់សម្ពាធមកលើចិនឱ្យចុះចូល។

ជារួមប៉េកាំងប្រហែលជាស្វាគមន៍ឯកអគ្គរដ្ឋទូតអាមេរិកថ្មីនេះដោយចិត្តស្ងប់។ គាត់មិនមានបំណងប្រាថ្នានិងថាមពលវិជ្ជមានដើម្បីធ្វើឱ្យទំនាក់ទំនងចិន-អាមេរិកប្រសើរឡើងនោះទេ ប៉ុន្តែគាត់ក៏មានឧបករណ៍តិចតួចដែរ ដើម្បីវាយប្រហារចិនដែលគាត់បានប្រាប់សភាអាមេរិក និងឥស្សរជននយោបាយរបស់វ៉ាស៊ីន-តោន។ ពួកគេក៏គួរតែបញ្ជូនលោក Burns ទៅប្រទេសចិនដោយចិត្តស្ងប់ដែរ ដោយសារក្រុងវ៉ាស៊ីនតោនមិនអាចរកវិធីឈ្នះការប្រយុទ្ធជាមួយចិន។ តើពួកគេអាចរំពឹងថាលោក Burns ធ្វើអ្វីបាន ?

**ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត**

# ២- ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនានាដែលឆ្លុះបញ្ចាំងពី រដ្ឋប្រហារនៅភូមាទម្លាក់លោកស្រី អ៊ុង សានស៊ូជី

ព្រឹត្តិការណ៍រដ្ឋប្រហារដែលផ្ទុះឡើងនៅប្រទេសភូមា(ម៉ាយ៉ាន់ម៉ា)កន្លងមកនេះគឺក្រុមមេដឹកនាំយោធា បានទម្លាក់លោកស្រី អ៊ុង សានស៊ូជី ពីតំណែងប្រធានក្រុមប្រឹក្សារដ្ឋ( State Counsellor) និងរំលាយស្ថាប័ន នានារបស់លោកស្រី ដែលធ្វើឲ្យផ្អើលពិភពលោកមិនស្ទើរ! ។

បច្ចុប្បន្ន ប្រទេសលោកខាងលិច រួមទាំងអង្គការសហប្រជាជាតិ បានទាមទារឱ្យដោះលែងលោកស្រី ស៊ូជី ជាបន្ទាន់ និងរៀបចំឱ្យឲ្យមានរបបប្រជាធិបតេយ្យឡើងវិញ។

ស្ថិតក្នុងបរិការនេះបើគេនាំគ្នាងាកក្រោយក្រឡេកមើលព្រឹត្តិការណ៍នានានៅប្រទេសភូមាចាប់ពីអំឡុង ពេលដែលចក្រភពអង់គ្លេសកាន់កាប់ប្រទេសមួយនេះហើយបានប្រគល់ឯករាជ្យនាឆ្នាំ១៩៤៨បន្ទាប់ពីសង្គ្រាម លោកលើកទី២មកប្រទេសមួយនេះត្រូវស្ថិតនៅក្នុងបរិបទគ្រប់គ្រងដោយរបបផ្តាច់ការនិងយោធានិយមដែល ដឹកនាំដោយលោកប្រធានាធិបតី និងមេទ័ពផ្តាច់ការ លោក នេវិន តាំងពីឆ្នាំ១៩៥៨-១៩៧៤។ក្នុងសម័យនោះ ទៀតសោត ប្រទេសនេះបានល្បីល្បាញ ដោយសារមានឥស្សរជនជាន់ខ្ពស់មួយរូប គឺលោក អ៊ូ ថាន់ (U Thant) បានត្រូវតែងតាំងជាអគ្គលេខាធិការអង្គការសហប្រជាជាតិចំនួន២អាណត្តិ ពីឆ្នាំ១៩៦១-១៩៦៦ និង ពីឆ្នាំ១៩៦៦-១៩៧១! ដូចនេះសំនួរសួរថា តើពិភពលោកមានការអើរទាំជាមួយប្រទេសភូមាថា ដឹកនាំក្រោម របបផ្តាច់ការយោធាឬទេ?

ចំពោះបញ្ហានេះនរណាក៏ដឹងដែរថាពិភពលោកពុំបានអើរទាំប្រទេសភូមាទេរហូតដល់ឆ្នាំ១៩៨៨ទើប មានព្រឹត្តិការណ៍នាំគ្នាប៉ះបោរបាតុកម្ម បំផុសបំផុលទម្លាក់របបផ្តាច់ការយោធា ដែលគេសង្កេតឃើញប្រទេស ភូមា មានបែងចែកជាគោលការនិយមពីរ៖ ១-ក្រុមនយោបាយដែលសមាជិកភាគច្រើនជាមេទ័ព និង ២- ក្រុម អ្នកនយោបាយដែលនិយមលទ្ធិប្រជាធិបតេយ្យ គឺក្រុមលោកស្រី អ៊ុង សានស៊ូជី ជាកូនស្រីលោក អ៊ុង សាន ដែលកាលណោះគេចាត់ទុកថាជាជាបិតាជាតិ អ្នកទាមទារឯករាជ្យពីចក្រភពអង់គ្លេស។

យើងយល់ថាចំពោះព្រឹត្តិការណ៍ដែលកំពុងផ្ទុះឡើងនេះគឺពិតមានការពាក់ពន្ធ័នឹងព្រឹត្តការណ៍ជាប្រវត្តិ សាស្ត្រ ចាប់តាំងពីពេលបោះឆ្នោតឆ្នាំ១៩៩០មកម្ល៉េះ គឺរវាងក្រុមលោកស្រី ស៊ូជី ប្រធានគណបក្សសម្ព័ន្ធជាតិ ដើម្បីប្រជាធិបតេយ្យ (NLD/National League for Democracy)ដែលបង្កើតនៅឆ្នាំ១៩៨៨ ដែលលោកស្រី ជាអគ្គលេខាធិការ។

សូមរំឭកផងដែរថា មុនព្រឹត្តិការណ៍ឆ្នាំ១៩៩០ ប្រទេសនេះត្រូវបានទទួលឯករាជ្យពីប្រទេសអង់គ្លេស នៅឆ្នាំ១៩៤៨ ហើយមានការបោះឆ្នោតជាច្រើនលើក រហូតដល់រដ្ឋប្រហារយោធានៅឆ្នាំ១៩៦២ ដែលពួក យោធា ក្រោមការដឹកនាំរបស់លោកប្រធានាធិបតី នេវិន(Newin) រហូតនៅឆ្នាំ១៩៧៤ និងជាបន្តបន្ទាប់មក ទៀតប្រទេសមួយនេះត្រូវបានដឹកនាំដោយគណបក្សតែមួយនិងជារបបយោធាផងដែររហូតដល់ឆ្នាំ១៩៨៨។

ដូចបានលើកមកនេះ សំនួរសួរថាហេតុអ្វីក៏ពិភពលោក ពិសេសលោកខាងលិច និងអង្គការសហប្រជា ជាតិស្ងាត់ចឹម និងមិនមានប្រតិកម្មអីបន្តិច?

សូមរំឭកថានាអំឡុងពេលនោះដែរ លោក អ៊ូ ថាន់ (U Thant) ជាឥស្សរជនជាន់ខ្ពស់នៃប្រទេសភូមា បានត្រូវតែងតាំងជាអគ្គលេខាធិការអង្គការសហប្រជាជាតិចំនួន ២អាណត្តិជាប់គ្នា គឺឆ្នាំ១៩៦១-១៩៦៦ និង ពីឆ្នាំ១៩៦៦-១៩៧១! ពិភពលោកនៅតែរអ៊ូករអឺនជាមួយប្រទេសភូមា ក្រោមរបបផ្តាច់ការយោធា!រហូតដល់ ឆ្នាំ១៩៨៨ ទើបប្រជាជនបះបោរទូទាំងប្រទេស នាំគ្នាធ្វើបាតុកម្មបំផុសបំផុលទម្លាក់របបផ្តាច់ការយោធាមួយ

នេះ! កាលណោះលោកស្រី ស៊ូជី ជាអគ្គលេខាធិការគណបក្ស ដែលទើបនិងបង្កើតថ្មីគឺ NLD -National League for Democracy សម្ព័ន្ធជាតិដើម្បីប្រជាធិបតេយ្យ ដែលគាត់ត្រូវបានគាំទ្រដោយអតីតមេទ័ពយោធាធំៗ ដែលមិនពេញចិត្តនឹងថ្នាក់ដឹកនាំយោធា។

បន្ទាប់ពីមហាបាតុកម្មឆ្នាំ១៩៨៨មកអាជ្ញាធរភូមាបានអនុញ្ញាតិឱ្យមានការបោះឆ្នោតសកលដែលបានប្រព្រឹត្តទៅនាខែឧសភា ឆ្នាំ១៩៩០ ដែលកាលណោះ គណបក្សលោកស្រី ស៊ូជី ឈ្នះភ្លូកទឹកភ្លូកដីលើសពី ៨១ % គឺ ៣៩២អាសនៈ លើ៤៩២អាសនៈ។ ជាអកុសលលទ្ធផលនេះ ត្រូវបានអាជ្ញាធរយោធាប្រកាសមិនទទួលស្គាល់មិនព្រមប្រគល់អំណាចទៅឱ្យគណបក្សលោកស្រីដែលឈ្នះឆ្នោត។កាលណោះដែរមហាប្រទេសលើពិភពលោកទាំងអស់ រួមទាំងអង្គការសហប្រជជាតិ បានស្រែកថ្កោលទោសយ៉ាងខ្លាំង។ មិនតែប៉ុណ្ណោះទៀតសោត លោកស្រី ស៊ូជី ត្រូវយោធាចាប់ឃាត់ខ្លួន តាំងពីមុនថ្ងៃបោះឆ្នោត គឺឃុំក្នុងផ្ទះមិនឲ្យចេញក្រៅ អស់អំឡុងពេលយ៉ាងហោចណាស់១៥ឆ្នាំ។

បន្ទាប់មកក៏មានការបោះឆ្នោតសកលម្តងទៀត នាឆ្នាំ២០១០ ដែលពួកយោធានិយម បានប្រកាសថាជាដំណើរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ តែពេលនោះគណបក្ស NLD របស់លោកស្រី ស៊ូជី បាន boycutt ការបោះឆ្នោតនេះ។ ពេលនោះ ក្រុមបក្សកណ្តាលនិយមរបស់លោក ធៀន សេន ( Thein Sein ) ត្រូវបានឈ្នះឆ្នោតហើយលោកត្រូវបានតែងតាំងជាប្រធានាធិបតីក្នុងអាណត្តិ២០១១-២០១៦ដែលកាលណោះសហរដ្ឋអាមេរិកក៏បានទទួលស្គាល់រដ្ឋាភិបាលថ្មីនេះដែរ។ រហូតដល់ឆ្នាំ២០១២ ប្រទេសភូមាបានប្រកាសការ បោះឆ្នោតពាក់កណ្តាលអាណត្តិ by-election គណបក្សលោកស្រីស៊ូជី បានចូលប្រកួតដែរ បានឈ្នះអាសនៈស្ទើរតែទាំងអស់ ទទួលបាន៤៣ លើ៤៤ !

រហូតដល់ឆ្នាំ២០១៥ មានការបោះឆ្នោតសកលជាថ្មីទៀត ដែលពេលនោះគណបក្សលោកស្រី NLD ឈ្នះភ្លូកទឹកភ្លូកដីម្តងទៀតគឺទទួលបាន៨៦%ហើយលោកស្រីក៏បានទទួលតំណែងជា"ប្រធានក្រុមប្រឹក្សារដ្ឋប្រទេសភូមា មានឋានៈស្មើនាយករដ្ឋមន្ត្រី" ព្រោះថារដ្ឋធម្មនុញ្ញមិនអនុញ្ញាតិឱ្យលោកស្រី មានតំណែងជាប្រធានាធិបតីទេ។

ក្នុងអាណត្តិហ្នឹងនៅឆ្នាំ២០១៩ លោកស្រីស៊ូជីត្រូវអន្តរជាតិទម្លាក់កំហុសថាបានអនុញ្ញាតឱ្យពួកយោធាធ្វើបាបជនជាតិភាគតិច " រ៉ូហ៊ីងយ៉ា" ម៉ូស្លីម នៅភូមា ហើយលោកស្រី ត្រូវបានតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ( ICC ) កោះហៅសួរចម្លើយ ករណី"សម្លាប់រង្គាល"ដែលញុំាងឱ្យពួកម៉ូស្លីមនេះរត់គៀសខ្លួនទៅជ្រកកោននៅប្រទេសបង់ក្លាដេស ប្រមាណជាង១លាននាក់ ដែលខណៈនោះគាត់ត្រូវឆ្លើយការពារពួកយោធា លើបទចោទ "សម្លាប់រង្គាល " នេះ។

ឥឡូវចូលដល់ព្រឹត្តិការណ៍ចុងក្រោយថ្មីៗនេះដែលរដ្ឋអំណាចយោធាធ្វើរដ្ឋប្រហារទម្លាប់លោកស្រីដែលមានមតិជាច្រើនចោទសួរថា តើពួកយោធាភូមានឹងបកក្រោយប្រគល់អំណាចឲ្យលោកស្រីវិញឬទេ? តើពួកយោធានឹងស្តាប់ការអំពាវនាវរបស់អង្គការសហប្រជាជាតិ ឬប្រទេសលោកសេរីមហាអំណាចមួយចំនួន ដែលចាប់ផ្តើមដាក់ទណ្ឌកម្មជាបណ្តើរៗលើមេដឹកនាំយោធាមួយចំនួនដែរឬទេ?

បើយើងពិនិត្យមើលសភាពការណ៍បច្ចុប្បន្ន យើងឃើញថា ពួកយោធាដូចជាមិនបន្ធូរដៃទេ! ប៉ុន្មានថ្ងៃចុងក្រោយនេះ ពួកបាតុករបានកញ្ជ្រោលយ៉ាងខ្លាំង រហូតដល់មានការបាញ់ប្រហារដល់ស្លាប់ជាច្រើននាក់។ សភាពការណ៍ចេះតែក្តៅទៅៗ ...សុំរងចាំមើលតទៀត!។

*ដោយ វ៉ែន្ន សណ្តាប់*

# កំណើតល្បែងប្រណាំងទូក ង និង ការប្រណាំងទូក ង នៅកម្ពុជាក្រោម

នៅស្រុកបាសាក់ ខេត្តឃ្លាំង (កូសាំងស៊ីន) ល្បែងប្រណាំងទូក ង ជាល្បែងមួយសម្រាប់ប្រទេសជាតិមានតៗមកជាច្រើនសតវត្សណាស់មកហើយ ទាំងមានជាទម្លាប់ក្នុងស្រុកបាសាក់ ដល់មកសព្វថ្ងៃនេះ។ បើតាមផ្ទៃនៃរឿងទូក ង នោះ បានពិនិត្យតាមគោលដើម គឺមិនមែនទូកដែលសម្រាប់ប្រណាំងលេងនោះទេ គឺជាទូកជំនិះទ័ពស្រួចជើងទឹក សម្រាប់ធ្វើសឹករបស់ស្ដេចត្រាញ់ខ្មែរ នៅស្រុកបាសាក់ជំនាន់បុរាណ។ រឿងនេះ គេបានផ្ទៀងផ្ទាត់តាមទំនៀមទម្លាប់ខ្លះបានស្រង់យកសេចក្ដីដែលទាក់ទាមក្នុងរឿងទូកងដែលមានក្នុងសៀវភៅប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ ដែនកម្ពុជាក្រោម ស្រុកបាសាក់ ខេត្តឃ្លាំង (កូសាំងស៊ីន) ត្រង់ទំព័រ២៥ និង ៣២ មាននៅក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យរង ខេត្តឃ្លាំង សៀវភៅប្រវត្តិសាស្ត្រនេះ នឹងមានបញ្ជាក់ឱ្យច្បាស់ទៅខាងចុង។

## ១. ទិដ្ឋភាពប្រវត្តិ

មានសេចក្ដីដំណាលក្នុងទំព័រ២៥ នោះថា កាលពុទ្ធសករាជ២០៧១ គ្រិស្តសករាជ ១៥២៨ គ្រានោះព្រះបាទអង្គចន្ទទី១ ស្ដេចតាំងបន្ទាយលង្វែកជាទីក្រុង ព្រះអង្គជាព្រះមហាក្សត្រប្រកបដោយព្រះរាជហឫទ័យសប្បុរស ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដោយមាំមួន។ ក្នុងសម័យនោះ ចំណែកស្រុកបាសាក់ មានអធិករង្សាព្រះនាម ទេន ធ្វើជាចៅហ្វាយស្រុក លោកទទួលអនិច្ចកម្ម រឿងនោះក៏ជ្រាបដល់ព្រះបាទអង្គចន្ទ ព្រះអង្គទ្រង់ប្រទានយសសក្ដិដល់ព្រះរាជបម្រើជិតស្និទ្ធម្នាក់ ឈ្មោះ ពញាតាត ជាទីស្និទ្ធភូបាលហើយព្រះរាជទាន ឱ្យមានអំណាចជាស្ដេចត្រាញ់ក្នុងស្រុកបាសាក់។ លោកស្និទ្ធភូបាល«តាត»ទៅធ្វើជាស្ដេចត្រាញ់នៅស្រុកបាសាក់នោះ លោកបានចាត់ការរៀបចំស្រុក ឱ្យមានជាមណ្ឌលមួយនៅកណ្ដាល និងមណ្ឌល៤ទៀតនៅទិសទាំង៤។ ឯមណ្ឌលកណ្ដាលហៅថារាស្ត្រក្នុងរបង សម្រាប់បម្រើស្ដេចត្រាញ់ ហើយតាំងឱ្យមានមន្ត្រីរក្សាមណ្ឌលនោះ ៤ទៀត។ ទី១-មន្ត្រីសេនាបរទេស ត្រួតត្រាទិសខាងកើត តាមទន្លេបាសាក់ទៅដល់សមុទ្រ។ ទី២-មន្ត្រីអធិក-សេនា ត្រួតត្រាទិសខាងត្បូង តាមសមុទ្របាក់លីវ ក្រមួនស។ ទី៣-មន្ត្រីអញ្ជិតសេនា ត្រួតត្រាទិសខាងលិច តាមសមុទ្រក្រមួនស ដល់ខេត្តពាម។ ទី៤-មន្ត្រីសេនាសង្គ្រាម ត្រួតត្រាទិសខាងជើង តាមទន្លេបាសាក់ ដល់មាត់ជ្រូក ខេត្តមាត់ជ្រូក (ចូវដុក)។

ក្នុងសម័យរៀបមន្ត្រីឱ្យត្រួតត្រាទិសទាំង៤នោះរួចហើយ លោកស្និទ្ធភូបាលបានចាត់ឱ្យរៀបក្បួនទ័ពច្បាំងជើងគោកនិងជើងទឹកក្នុងមណ្ឌលទាំង៤ទិសនោះទៀតហើយបញ្ញត្តឱ្យគ្រឿងសាស្ត្រាវុធសម្រាប់ទាហានឯរាស្ត្រប្រជាគ្រប់ភូមិ ក៏ត្រូវមានប្រដាប់ការពារ ដូចគ្នាទាំងអស់ គឺធ្នូ ស្នា ដាវ លំពែង ផ្គាក់ ខែល ...។ ទាហានជើងគោកដែលមានមេទាហានមានងារជាសេនាពិជ័យសង្គ្រាមមានសេនារងបីនាក់ទៀតគឺមេកង១០

មេកងរយ មេកងពាន់។ ឯគ្រឿងស្លៀកពាក់ទាហានទាំងនោះ សំពត់ចងក្បិន អាវរាងឈាយ ឯឡេវអាវគេច្រើន ប៉ាក់នឹងសំពត់លឿងឬក្រហមគេច្រើននិយមប្រើឡេវ៩-១១-១២ចំណែកឯគ្រឿងសម្គាល់យសសក្តិរបស់ទាហាន នោះ គេប៉ាក់សំពត់ក្រហមជាសម្គាល់នៅកអាវ បើជានាយថៅហ្វាយនោះ ត្រូវមានឆ្នូតសំពត់១ជាន់ ឬ២ជាន់ ឬ៣ជាន់ តាមបុណ្យសក្តិរបស់នាយទាហាន។ ទាហានជើងទឹក ក៏មានគ្រឿងសាស្ត្រាវុធ ដូចគ្នានឹងទាហាន ជើងគោកដែរ។ ប៉ុន្តែខុសគ្នាត្រង់សម្លៀកបំពាក់ ខោស្នាប់ភ្លៅ អាវបំពង់ត្រឹមចង្កេះ ពួកទាហានជើងទឹកចែក ជា៣ក្រុមតទៅទៀតគឺ :

-ក្រុមទី១: ហៅទ័ពស្រួច ហាត់ច្បាំងនឹងទូកអុំ សណ្ឋានដូចទូក ង យើងសព្វថ្ងៃនេះ។

-ក្រុមទី២: ហៅទ័ពជំនួយ ហាត់ច្បាំងនឹងទូកចែវពីរជួរ ទ្រង់ទ្រាយដូចទូកចែវប្រណាំងសព្វថ្ងៃនេះ។

-ក្រុមទី៣:ហៅទ័ពបាសាក់គឺទូកធំមានដំបូលមានចែវមានក្តោងសណ្ឋានដូចទូកប៉ុកចាយតែរាងស្តួច វែង ដំបូលតែមួយកាត់ខាងមុខ ឥតមានជញ្ជាំងទេ សម្រាប់ដាក់ជើងចែវម្ខាងមានចែវ៨ ឬចែវ១០ ទូកនេះ សម្រាប់ដាច់ស្បៀងអាហារបម្រុង នៅមានប្រើក្នុងរវាង៣០ឬ៤០ឆ្នាំមុន ឥឡូវហាក់ដូចជាចោលទូកនេះ បាត់ អស់ទៅហើយ។ របៀបបង្ហាត់ចម្បាំង និងរក្សាពលរដ្ឋជាភារៈមន្ត្រីទាំង៤ទិស ចំណែកឯមន្ត្រីទាំង៤នោះ ត្រូវ បិតនៅក្រោមឱវាទលោកស្និទ្ធភូបាលគ្រប់ជំពូក។ សម័យនោះ មានបញ្ញាត្តច្បាប់សម្រាប់ស្រុកមួយបែបគឺ :

ក-កំណត់នៅថ្ងៃពេញបូណ៌មីខែអស្សុជ រដូវចេញព្រះវស្សា កិច្ចនោះ ត្រូវអ្នកព្រឹទ្ធាចារ្យនិងនាម៉ឺនព្រះ ពញា គ្រប់ខេត្តទាំងអស់ មកជួបជុំគ្នានៅមន្ទីរលោកស្និទ្ធភូបាល ហើយលោកនាំអ្នកទាំងអស់នោះទៅកាន់ ទីអារាម ដើម្បីធ្វើសីលទានតាមច្បាប់ព្រះពុទ្ធសាសនា។

ខ-កំណត់នៅថ្ងៃពេញបូណ៌មីខែកត្តិក រដូវអកអំបុក នោះមន្ត្រីទាំង៤ទិស កេណ្ឌទាហានជើងគោក ជើងទឹក មកប្រជុំនៅមុខបន្ទាយស្តេចត្រាញ់ ដើម្បីប្រឡងឫទ្ធីគ្នាមួយថ្ងៃមួយយប់។ ចំណែកទាហានជើងទឹក ឱ្យទៅប្រឡងឫទ្ធីឯទន្លេពាមកន្តោ ក្នុងខេត្តឃ្លាំង ត្បិតកន្លែងនោះជាទីប្រជុំផ្លូវទឹកធំ និងទៅមកបានដោយ ងាយ។

តាមលក្ខន្តិកសញ្ញានោះ ត្រូវមួយឆ្នាំប្រជុំត្រូវធ្វើការពីរលើក។ អំពីលោកស្និទ្ធភូបាល តាត ជាទី ស្តេចត្រាញ់នៅស្រុកបាសាក់ឃើញមានក្នុងសារតាលោកអធិកវង្សាអ្នងប្រាប់ថាលោកស្និទ្ធភូបាលបានចាត់ការ ថែរក្សាស្រុកទាំងប៉ុន្មាន ដូចរៀបរាប់មកខាងលើហើយនោះ តាមក្បួនលោក ក្រឡាពាសព្រះនាម មោះ ដែល ធ្វើជាស្តេចត្រាញ់ក្នុងដែនបាសាក់ ក្នុងរាជព្រះបាទបទុមសុរិយវង្ស ទ្រង់មានឫទ្ធិចេស្តាខ្លាំងណាស់។ (សេចក្តី ត្រង់នេះ សូមអានសៀវភៅប្រវត្តិសាស្ត្រទំព័រ៣២)។ កាលលោកស្និទ្ធភូបាល តាត រៀបកិច្ចការរក្សាស្រុកយក តាមក្បួនលោកក្រឡាពាសមោះនោះទទួលនឹងស្រុកក្សេមក្សាន្តមិនដែលមានចោរឬសឹកសត្រូវអ្វីក្នុងប្រទេស ម្តងសោះ ឯការហ្វឹកហាត់ធ្វើសឹកសង្គ្រាមដោយក្បួនទូកនោះ លុះយូរៗទៅក៏ក្លាយជាទំនៀមប្រណាំងទូកទៅ វិញ។ លោកស្និទ្ធភូបាលដល់កំណត់ជរាហើយ ក៏ទទួលអនិច្ចកម្មទៅ លោកមានបុត្រាម្នាក់ឈ្មោះពញា ឡុង ក៏ ទទួលទីជាអធិកវង្សាឡើង។ លោកនេះក៏បានរៀបចំស្រុកទេសតាមតម្រាយដើមរៀងមក ពេលដែលជរាទៅ លោកមិនមាន បុត្រាបុត្រីនឹងស្នងលោកតទៅទៀតឡើយ។ សម័យនោះ ក្នុងរាជព្រះជ័យចេស្តា ទ្រង់គង់នៅ ឧត្តុង្គមានជ័យលុះទ្រង់ជ្រាបថានៅស្រុកបាសាក់មិនមាននាម៉ឺនព្រះពញានឹងត្រួតត្រាស្រុកតទៅទៀតទេទើប

ទ្រង់ត្រាស់ប្រើម៉ឺនជ័យ ទីជាចៅពញាទេស្សវង្សា ឱ្យទៅត្រួតត្រាស្រុកនោះ ស្រុកក៏បរិបូណ៌ដោយភោគសម្បត្តិ មហាជនទាំង ឡាយក៏សុខសប្បាយ ចំណែកឯច្បាប់សម្រាប់ស្រុក ក៏បណ្ដែតបណ្ដោយរៀរពោយបាត់អស់ទៅ ឯការប្រឡងទូក ក៏ក្លាយទៅជាល្បែងប្រណាំងលេងទៅវិញ។ យើងនឹងរៀបរាប់ពីឈ្មោះចៅហ្វាយស្រុក ដែលធ្លាប់បានលេងទូក តៗមកនោះ :

| | |
|---|---|
| -ទី១: ពញា តាត ទីជា ស្និទ្ធភូបាល | -ទី២: ពញា ឡុង ទីជា អធិករង្សា |
| -ទី៣: ម៉ឺន ជ័យ ទីជា ចៅពញាទេស្សវង្សា | -ទី៤: ពញា ពេជ្រ ទីជា អធិករង្សា |
| -ទី៥: ពញា ម៉ៅ ទីជា អធិករង្សា | -ទី៦: ពញា តាតទី២ ទីជា អធិករង្សា |
| -ទី៧: ម៉ឺន សួរ ទីជា អធិករង្សា | -ទី៨: ចៅហ្វាយ ណឹម ទីជា អធិករង្សា |
| -ទី៩: ចៅហ្វាយ សុខ ទីជា អធិករង្សា | -ទី១០: ចៅហ្វាយ អួង ទីជា អធិករង្សា |
| -ទី១១: ចៅហ្វាយ អូ ទីជា អធិករង្សា | |

បើតាមសារតាថា ចៅហ្វាយស្រុកទាំង១១រូបនេះ សុទ្ធតែបានទទួលយសសក្តិ អំពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនៅក្រុងកម្ពុជារៀងៗមក។កាលលោកចៅហ្វាយអូធ្វើជាចៅហ្វាយស្រុកក្នុងព.ស.២៤២៣ គ.ស.១៨៨០ បានតែពីរឆ្នាំក៏ឈប់ធ្វើទៅ។ ចាប់ដើមពីឆ្នាំនោះមក មិនមាននាយម៉ឺនអំពីស្រុកខ្មែរ ទៅត្រួតត្រាស្រុកនោះទៀតឡើយ។ ចំណែកឯទំនៀមទម្លាប់ផ្សេងៗរបស់ខ្មែរ ឃើញនៅតែល្បែងទូក ង នេះមួយទេ ដែលមានលេងរៀងរាបមកមិនអាក់ខានឡើយ។ អុងភូ សឺន ឌៀប (១) (ពាក្យ អុងភូ ងារខាងកម្ពុជាក្រោម គឺប្រតិភូរដ្ឋបាល) លោក សឺន ឌៀប ឡើងជាអុងហៀន(ភូឈ្នួយចៅហ្វាយស្រុក) ក្នុងព.ស.២៤៣១ គ.ស. ១៨៨៨ លោកបានរៀបក្បួនទំនៀមទម្លាប់ខ្មែរជាច្រើន ឯល្បែងទូក ង នោះ លោកជានាយកចេញចាត់ការរៀបលេង ឱ្យមានសណ្ដាប់ធ្នាប់ល្អ ទូក ង ក្នុងខេត្តឃ្លាំង បាក់លីវ ក្រមួនស ក៏រឹងរឹតតែកើនច្រើនឡើងទៀត ជំនាងទូក ង ទាំងប៉ុន្មានខេត្តក្នុងស្រុកបាសាក់កាលនោះមានប្រវែងពី១៨ដល់២១ម៉ែត្រ ក្បាលនិងកន្សៀស្រៀវង ឡើងជាងទូកធម្មតា ក្បាច់រចនាក៏ច្រើនបែប ច្រើនពណ៌ជាងចំណុះទូកមានពី៤៨ដល់៥៥នាក់។ របៀបលេងល្បែងទូក ង គឺក្នុងមួយឆ្នាំលេងពីរដង នៅរដូវចេញវស្សា និងរដូវអកអំបុក មកប្រជុំគ្នានៅទន្លេពាមកន្លោ។ ក្នុងការអុំទូកពីរលើកនេះមានទូកមួយពួកឈប់នៅស្រុកអំពូយាមានស្ពានមួយវែងទន្លេក៏ទូលាយ នៅមាត់ទន្លេទាំងសងខាង មានផ្លូវចេញចូលស្រួល អុំនៅទីនេះមួយយប់ថ្ងៃកោរ ហើយទើបបបួលគ្នាទៅលេង នៅពាមកន្លោ។ ដល់មកព.ស. ២៤៤១ គ.ស.១៩០៤ លោក សឺន ឌៀប ឡើងសក្តិជាអុងភូ ក៏បានទទួលងារធ្វើជាសេនាបតីនៅក្រុងភ្នំពេញទៅ។ ក្រោយនោះ លោក ឡឹម ឯម ជាបុត្រារបស់លោក សឺន ឌៀប បានទទួលកាន់កាប់ទំនៀមទម្លាប់នោះតទៅទៀត។ លោកដុកភូសី ឡឹម ឯម (ពាក្យថា ដុកភូសី = ចៅហ្វាយខេត្ត) លោក ឡឹម ឯម បានឡើងទីជាដុកភូសី នៅព.ស.២៤៦៦ គ.ស.១៩២៣ លោកក៏បានធ្វើការតាមទំនៀមទម្លាប់រៀងមក។ ដល់រដូវចេញព្រះវស្សា លោកអញ្ជើញទៅរៀបលេងទូក ឱ្យមានរបៀបរៀបរយល្អមើល ហើយសប្បាយជាងបែបបទ ដែលលេងអំពីមុនៗមកផង ពីព្រោះពេលយប់ មានអុជប្រទីប ហែផ្កាភ្លើង ដោយក្បួន ទូក ប្រគំភ្លេងលេងជាទីសប្បាយរីករាយគ្រប់ៗគ្នា។ នៅឱកាសលេងទូកក្នុងរដូវចេញព្រះវស្សា កាលព.ស.២៤៦៧ គ.ស.១៩២៤ មហាជនទាំង

មកប្រជុំគិតគ្នាថា ទំនៀមលេងទូកនេះ គឺមានមកអំពីជីដូនជីតាយើងរាល់ៗគ្នា ចំណែកមនុស្សដែលមកលេង ឆ្នាំនេះ ប្រហែលជាមួយម៉ឺនរូប ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ចំណែកឯទូករ៉ើត ដំបូលកឹង ចែវ អុំ ប្រហែលជាង មួយពាន់ទូក ល្អមយើងរួមគ្នាសន្មតល្បែងនេះ ឱ្យបានស្រួលតាមបែបភាពអារ្យប្រទេស ក្នុងសម័យនេះផង។ ក្នុងពេលសន្និបាតនោះ បានព្រមព្រៀងគ្នាថាដូច្នេះ ៖

-ទី១.រដូវចេញព្រះវស្សា មានប្រណាំងទូក បែហ្គាភ្លើង បណ្តែតកន្ទោងលើទឹក សន្មតថាធ្វើសក្ការៈបូជា រំលឹកដល់ព្រះពុទ្ធបាទ ក្នុងគង្គាមហានទី។

-ទី២. រដូវអកអំបុក របៀបទៅលេងដូចគ្នាសន្មតហៅថា បុណ្យសំពះព្រះខែ ។

-ទី៣. រដូវចេញវស្សា ត្រូវទៅលេងនៅពាមកន្តោ តាមទំនៀមចាស់រៀងមក។

-ទី៤.រដូវអកអំបុក ត្រូវទៅលេងឯព្រែកអំពូយា ត្បិតយើងគិតរៀបទីកន្លែង និងអញ្ជើញនាម៉ឺន

អ្នកមុខអ្នកការទៅលេងផង ការដែលគិតនោះ ក៏ទទួលស្រុះស្រួលទាំងអស់គ្នា។

ដល់គ.ស.១៩២៨ ក៏ចោលទីកន្លែងពាមកន្តោ ហើយឈប់អុំទូក នៅរដូវចេញព្រះវស្សា រហូតមកដល់ សព្វថ្ងៃ នៅលេងតែរដូវអកអំបុក។ (ការសន្មតនេះ មិនឃើញមានច្បាប់អ្វីទេ គឺកើតដោយមហាជនធ្វើមតិទុក មក)។ ទីកន្លែងធ្លាប់ប្រណាំងទូកពីបុរាណរៀងមកនោះ ឈ្មោះពាមកន្តោ នៅស្រុកកំពង់ដូង ហៅថា ថាម ឌូង ខណ្ឌាញៀវ៉ា ទីរួមខេត្តឃ្លាំង មានពាមបែកជាបី ពាមមួយទៅខេត្តពលលាវ (បាក់លីវ) មួយទៅខេត្តក្រមួនស មួយទៀតមកខេត្តឃ្លាំង ទទឹងពាមនោះប្រហែលពីររយម៉ែត្រ កន្លែងប្រណាំងទូកនោះ ទន្លេមានរបត់ត្រង់ល្អ ណាស់ ប៉ុន្តែកន្លែងនោះជាទីរហោស្ថាន មានតែព្រៃព្រឹក្សានិងសត្វផ្សេងៗ ទាល់តែដល់រដូវលេងទូកនោះ ទើប បរិបូណ៌ដោយមហាជនទាំងឡាយ ព្រមទាំងទំនិញលក់ដូរគ្រប់បែបគ្រប់យ៉ាង។ ក្នុង ពេលនោះ បើនឹងផ្ទៀប ទៅប្រហែលនឹងទីក្រុងមួយ ដ៏សម្បូរដោយភោគសម្បត្តិនិងសេចក្តីក្សេមក្សាន្ត ហេតុនោះ ទើបមហាជនទាំង ឡាយ បាក់ចិត្តទៅលេងកំសាន្តរៀងៗមក។ បែបបទដែលនឹងទៅលេងទូកតាមរដូវនោះសោត ក៏មិនចាំបាច់ បបួលឬសន្មតគ្នាឡើយ តែដល់រដូវធ្លាប់លេងហើយ ក៏រៀបចំស្បៀងអាហារ ទូកក្តារ ច្រវាចែវ តែរៀងរាល់ភូមិ រាល់ស្រុកទៅលេង អ្នកណាទៅដល់មុនគេ ក៏លេងមុន អ្នកទៅដល់ក្រោយ ក៏លេងបណ្តោយនឹងគ្នាទៅ តាមតែ ទំនើងចិត្ត និងស្រែកហ៊ោកញ្ជៀវខ្ញៀវខ្ញារ កញ្ច្រោកបោកបាចទឹកឮសន្ធឹកគឹកកង ទាំងថ្ងៃទាំងយប់ ចំណែក ពេលយប់មានអុជចង្កៀងគោមប្រទីបទៀនធូបគម្រៀបគ្នាជាជួរបែហ្គាភ្លើងដោយក្បួនទូកបណ្តែតកន្ទោងតាម ទឹក អុជកាំជ្រួចរន្ទាភ្លឺទៀន ពន្លឺប្រទីបបញ្ចាំងរស្មីភ្លឺព្រោងព្រាយ សាយទៅលើនភាល័យ បាចសាចរស្មីទៅខ្ទប់ ដោយព្រៃព្រឹក្សាលតាវល្លិ ដែលដុះជិតជុំហ៊ុំគ្រើយទាំងសងខាង រមិលមើលទៅក្នុងទឹកយល់ ស្រមោលមាន ពណ៌ក្រហម ស ខៀវ លឿង ហាក់ដូចជាឆ្វាយឆ្វាត់ព័ទ្ធព័ន្ធគ្នា ចំណែកខាងភ្លេងតូរ្យតន្ត្រីសោត ក៏ប្រគំសូរសព្ទ ទ្រហឹងអឹងកងរំពងប្រេងពី ទាំងព្រះសង្ឃដែលពួកទាយក ទាយិកាប្រាថ្នាចង់បានសេចក្តីសុខ ហើយនិមន្តឱ្យ សម្តែងតាមទូកបែហ្គាភ្លើងនោះក៏សម្តែងព្រះបរិត្តយ៉ាងឮឡាវិកគួរជាទីសប្បាយរីករាយដល់មហាជនទាំងឡាយ ក្នុងពេលនោះដែរ។ ក្បួនដែលដង្ហែផ្កាភ្លើងទៅមក ចំនួនតែពីរបីលើកប៉ុណ្ណោះ ក៏ឈប់ បង្អង់ទៅ នៅសល់តែ ប្រណាំងទូក ង គឺលេងទល់ភ្លឺ ទើបនាំគ្នាអង្គាសចង្ហាន់ប្រគេនព្រះសង្ឃជាការស្រេច។ បានជានាំគ្នាសន្មតថា តែដល់ពេលអកអំបុកក្នុងខែកត្តិកនោះ គេត្រូវតែរៀបសង់រោងឬបារាំ នៅត្រង់ក្បែរវត្ត អំពូយានោះ ដើម្បីនឹង

ធ្វើជាទីសម្រាប់ទទួលនាម៉ឺនដែលមកទស្សនាការលេង និងបង្ហាញល្បែងទាំងនោះដល់នានាជាតិផង។ លុះសន្មតគ្នាស្រេចហើយ ក្នុងវេលាថ្ងៃត្រង់ ត្រូវនឹងទឹកជំនោរជោរឡើងពីសមុទ្រមក ពួកជនដែលនៅខេត្តឃ្លាំង ក៏បណ្តែតទូកតាមខ្សែទឹកហូរទៅខេត្តនោះ។ឯបណ្តាជននៅខេត្តក្រមួនសក៏ទៅតាមពាមព្រែកអំពូយាបណ្តោយតាមខ្សែទឹកហូរជោរចូលទៅខេត្តនោះដែរ។ ចំណែកខាងបណ្តាជនខេត្តពលលាវ( បាក់លីវ )វិញត្រូវរង់ចាំទំរាំថ្ងៃរសៀល ទឹកនាចវិញ ទើបទៅតាមទឹកនោះបាន។

## ២. និដ្ឋភាពចំលាស់ប្តូរទីកន្លែង និងកំណែទម្រង់ឱ្យបានចម្រើន

ព្រែកអំពូយា នៅឃុំចាញ់គូ ទីរួមខេត្តឃ្លាំង ទីនោះនៅត្រង់ផ្លូវប្រទេសជាផ្លូវធំ មានចាក់កៅស៊ូល្អ ស្អាតណាស់ ចម្ងាយពីខេត្តឃ្លាំងប្រហែលជា១៧គ.ម. ទទឹងព្រែកមានទំហំជាងមួយរយម៉ែត្រ មានស្ពានដែកមួយធំទទឹងថ្ងៃ។ បើឈរហើយមើលទៅខាងកើតខាងលិច ឃើញព្រែកនោះត្រង់ល្អណាស់ នៅត្រង់ក្បាលស្ពានខាងត្បូង មានផ្ទះផ្សារពីរជួរបណ្តោយថ្នល់ ដែលឆ្ពោះទៅកាន់ខេត្តបាក់លីវ។ នៅខាងលិច មានផ្ទះផ្សារជាជួរៗបណ្តោយតាមមាត់ព្រែក មានវត្តលោកសង្ឃខ្មែរមួយ នៅចុងផ្សារខាងលិច ក្នុងទីផ្សារមានសាលាឃុំមួយខ្នង និងសាលាខណ្ឌមួយខ្នង។ ចំណែកត្រើយខាងជើង មានផ្ទះពីរបីជាន់ដែរ ប៉ុន្តែច្រើនតែផ្ទះអ្នកមានភោគសម្បត្តិគេសង់សម្រាប់នៅរបស់គេ ឯផ្សារនោះមានទំនិញលក់ដូរយ៉ាងបរិបូណ៌ដូចជាផ្សារធំៗឯទៀតដែរ។ ការរៀបចំទីកន្លែងថ្មី តែកាលណាជិតដល់រដូវអកអំបុក នៅទីនោះ មានលោក យឿង នី ជាចៅហ្វាយខណ្ឌ លោកចាត់ការរៀបចំឱ្យរាស្ត្រសង់រោងមួយ ចំនួនបីល្វែងសម្រាប់ទទួលនាម៉ឺន។ក្នុងទីវត្តឱ្យរៀបចំសាលាមួយ សម្រាប់ទទួលព្រះសង្ឃហើយលោកធ្វើចុតហ្មាយកំណត់ពេលវេលាអញ្ជើញលោកចៅហ្វាយខេត្តនិងនាម៉ឺនអ្នកមុខអ្នកការ។ លុះដល់ថ្ងៃពេញបូណ៌មីខែកត្តិក ដែលជារដូវអកអំបុក បណ្តាជនទាំងបីខេត្ត មកមូលជុំគ្នា អុំលេងកំសាន្តតាមធម្មតាដល់ពេលម៉ោងពីររសៀលត្រូវរៀបរោងទទួលមន្ត្រីឯសាលាវត្តជាស្រេចលុះជិតពេលម៉ោងបួនល្ងាចត្រូវផ្គូទូកជាគូៗ សន្មតសួរបាញ់កាំភ្លើង គ្រវីទង់ជ័យនៅមុខបារាំ ត្រូវអុំមួយគូម្តងៗ យកឈ្នះចាញ់។ ដល់ពេលម៉ោង៥រសៀល លោកចៅហ្វាយខេត្តនិងនាម៉ឺនអ្នកមុខអ្នកការអញ្ជើញទៅដល់ព្រមគ្នា ក៏ចាប់បាញ់កាំភ្លើង គ្រវីទង់ជាសញ្ញា ពួកអ្នកទូកអុំជាគូ យកឈ្នះចាញ់ដល់ចុងព្រាត ទោះឈ្នះក្តី ចាញ់ក្តី ទូកទាំងពីរនោះ ត្រូវអុំទន្ទឹមគ្នា ហោថាប្រាសច្រវាសាឡើងមកវិញ នោះមានអ្នកឈរកាន់គងវាយម្នាក់ ហើយមានអ្នកឈរច្រៀងបន្ទរជាពាក្យកាព្យឃ្លោង ឆ្លោះឆ្លងគ្នាជាពាក្យប្រលោម ចាក់ក្បាច់ឡូក ញាក់មុខដាក់គ្នាទៅមក ឯអ្នកឈរមើលទាំងសងខាងផ្លូវថ្នល់នោះ ក៏អើតករហង់ ចាំមើលនិងស្តាប់ចម្រៀងនោះ។ ឯអ្នកចំណុះទូក ង ទាំង៤៤ ឬ៤៨ នាក់ក៏អុំប្រាសច្រវាតិចៗ ហើយចាំទទួលពាក្យបន្ទរខាងចុងឃ្លាថា ហៃយើៗ ហៃយើៗ។ រួចហើយគេចាត់រង្វាន់ដល់ទូក ង ឯរង្វាន់ដែលឱ្យនោះ មានតែចំណីអាហារ ស្រា បាយ តាមមានតាមបាន។រួចអំពីនោះ ត្រូវលៀងនំ ទឹកតែដល់ក្រុមមន្ត្រីទាំងឡាយតទៅទៀត មានអុជកាំជ្រួចរន្ទាភ្ញីទៀត ហែផ្កាភ្លើងដោយក្បូនទូក ឯបែបដង្ហែផ្កាភ្លើងក៏ដូចគ្នា នឹងកាលដែលដង្ហែឯពាមកន្តោនោះដែរ។ក្នុងអារាមវិញ មានឧបាសក ឧបាសិកា នមស្សការសមាទានតាមរបៀបបវេណីតមក រួចមានឱ្យរង្វាន់ដល់ពួកម្ចាស់ ដែលដង្ហែផ្កាភ្លើងនោះទៀត ឯរង្វាន់សម្រាប់ឱ្យនោះ គឺពួកអ្នកជំនួញធ្វើការឃោសនាគ្នាទិញគ្រឿងប្រដាប់ផ្សេងៗចែកជារង្វាន់។នៅឱកាសចែករង្វាន់នោះមានលោកចៅហ្វាយខេត្ត លោកសួរអំពីទំនៀមទម្លាប់ខ្មែរ ដែលលេងទូកនេះជាសេចក្តីត្រួសៗ ពេលនោះលោក ដុកភូសី

ឡើម ឯម លោកក៏បាននិយាយពន្យល់អំពីទំនៀមទម្លាប់ខ្មែរ ដែលមានមកច្រើនសតវត្សមកហើយ ទើបពួកអ្នករាជការទាំងអស់គ្នា មានលោកចៅហ្វាយខេត្តជាដើម ទទួលត្រេកអររីករាយ ហើយពោលថា ល្បែងនេះគួររាប់បញ្ចូលក្នុងរឿងប្រវត្តិសាស្ត្ររបស់ប្រទេសបាន បើប្រសិនណាជារាជការមានធ្វើបុណ្យអ្វីមួយ គួរតែយកទៅលេងកំដរបុណ្យរាជការផងបានឬទេ? រាជការនឹងឱ្យរង្វាន់ក៏ ទើបលោកដុកភូសី និងជនជាតិខ្មែរទាំងអស់ក៏ទទួលព្រមព្រៀងក្នុងពេលនោះដែរ ។ ចាប់ដើមពីឆ្នាំនោះមក រាជការត្រូវការប្រជុំអុំទូកមួយឆ្នាំពីរដងឬបីដង គឺនៅថ្ងៃ១៤ ស៊ូយេត(កក្កដា) អុំម្តង ថ្ងៃ១១ ណូវ៉ែម (វិច្ឆិកា)ម្តង បើឆ្នាំណាធ្វើបុណ្យ មានតាំងតុលក់ទំនិញ (កៀកមេស)នោះ ត្រូវអុំឱ្យរាជការ៣ដង។ បើគិតរួមទាំងទំនៀមយើងពីរដងផង ត្រូវជាមួយឆ្នាំអុំ៤ដងឬ៥ដងក៏មាន រាជការតែងតែមានចែករង្វាន់ជាប្រាក់កម្រៃនិងរូបផ្សេងៗជាធម្មតា។ ការលេងល្បែងទូកនេះក៏កាន់តែចម្រើនឡើងជាដរាបមក មិនដែលអាក់ខានឡើយ សូម្បីតែស្រុកទេសមិនសូវសុខក្សេមក្សាន្តដូចកាលឆ្នាំ ១៩៤៥-៤៦-៤៧នោះដែលលំបាកដោយផ្លូវគមនាគមន៍ចុះឡើងរកគ្នានោះឯងក៏នៅតែមានលេងត្រង់កន្លែងដែលធ្លាប់លេងពីបុរាណនោះមកដែរ បើប្រកបដោយអន្តរាយច្រើនក៏នៅតែរកឧបាយលេងទាល់តែបាន ប៉ុន្តែលេងដោយភិតភ័យ។ បើកាលណាដល់វេរត្រូវលេងហើយ អ្នកដែលនៅស្រុកណាភូមិណា ក៏នាំគ្នាលេងនៅស្រុកនោះភូមិនោះទៅប៉ុន្តែមានកន្លែងខ្លះលេងបានតែវេលាថ្ងៃដល់ពេលយប់លេងពុំបានក៏មានដែរ។អំពីទូកវិញ បើកន្លែងណាមានទូក ង ក៏រៀបលេងតាមទំនៀមទៅ បើកន្លែងណាមានទូក ង ទេ គេយកសុទ្ធតែទូកចែវពីរឬចែវ៣-៤ហើយយកដីស្អិតមកបំពកលើក្បាលឬកន្សៃទូកធ្វើឱ្យរាងដូចជាទូកងមែនទែនទើបយកក្រដាសពណ៌ខៀវក្រហមលឿង បិតលើដីស្អិតនោះរួចស្រេចហើយ គេរៀបស្លាធម៌បាយសីនៅក្បាលទូករួចនាំគ្នាអុំទូកលេងតាមភូមិស្រុកទៅ សេចក្តីដែលរៀបរាប់មកនេះជាការពិតណាស់ មិនមានបញ្ចេញបញ្ចូលទេ។

## ៣. សេចក្តីបញ្ជាក់អំពីល្បែង និងជំនាងជំនិះទូក និងកម្មវិធី

ទូក ង នៅស្រុកបាសាក់ ក៏មានសណ្ឋានដូចទូក ង នៅកម្ពុជរដ្ឋដែរ ឯគ្រឿងប្រដាប់តាក់តែងទូក អ្នកជិះក្បាលទូក អ្នកច្រៀងបើកបទបន្ទរ មានប្លែកគ្នាខ្លះដូចនឹងរៀបរាប់តទៅនេះ : គេហៅថាណាមុខណាក្រោយនោះគឺសំពត់ពណ៌ផ្សេងៗ ទំហំប៉ុនទទឹងក្បាលឬកន្សៃបណ្តោយ ៥០-៦០ ស.ម. ដែលមានអង្កាំឬខ្សែសយឌិនប៉ាក់ជារូបផ្សេងៗ ហើយចងព្យួរ មានរំយោលផ្កាខ្ទម្ពពីរ នៅសងខាង នៅខាងក្បាល មានស្លាធម៌ដូងមួយ ទូកខ្លះទៀតមានរណ្តាប់ទៀន៥ធូប៥ហើយនិងបាយសីមានក្លស់រំភាយបាំងពីលើផង។មុននឹងដាក់ទូកចុះពីបង្គងរោង គេប្រគំភ្លេងច្រៀងរាំមួយយប់សិន ព្រឹកឡើងទើបដាក់ចុះទៅលេង ខាងក្បាលមានច្រវាពីរ សម្រាប់អ្នកជិះក្បាលដោតអមក្បាលទូកបន្ទាប់ពីអ្នកជិះក្បាល ហៅថា ស្នាឯក ជិះតែម្នាក់ឯងទេ បន្ទាប់មកហៅថាស្នាទឹមមានពីរនាក់ បន្ទាប់ស្នាទឹម ហៅកូនគូ គឺមួយគូៗរហូត ដល់កណ្តាលទូកនោះ មានខ្ទង់មួយគេចែកពីក្បាល ពីកន្សៃមកឱ្យខ្ទង់ស្មើភាគគ្នាហើយនៅសេសមួយគេហៅថាខ្ទង់ប្រាំធានខ្ទង់នោះអាចឱ្យគេដឹងសាច់ទូកទន់ឬរឹងលឿនឬមិនលឿនត្រូវថែមថយឈើទល់ឬមិនបាច់ថែមថយឈើទល់ត្រង់ខ្ទង់ប្រាំធាននោះមានមនុស្សអង្គុយពីរនាក់ម្នាក់វាយគង ម្នាក់ទៀតច្រៀងបើកបទបន្ទរ បន្ទាប់ពីខ្ទង់ប្រាំធានទៅហៅថាកូនលុត គឺលុតជើងម្ខាងលើខ្ទង់ជើងម្ខាងឈរជាគូៗ ទៅដល់អ្នកស្រង់យោង ៤-៥ ឬ៦នាក់ ក៏មាន ឯអ្នកស្រង់យោង ចាំស្តាប់អ្នកកាន់កន្សៃស្រែកថាឆ្វេងឬស្តាំ ឯអ្នកកាន់កន្សៃមើលអ្នកជិះក្បាល បើផ្លូអុំនឹងទូកដទៃអ្នកជិះក្បាលចាប់ច្រវាអុំ អ្នកកន្សៃក៏

អុំដែរ ដើម្បីជួយជាកម្លាំងឱ្យទូកស្ទុះ ឆាប់ដឹងចាញ់ឈ្នះ។ កម្មវិធីលេងទូកនេះ ជារបៀបមួយដែលកើតឡើង ដោយសាមគ្គីនៃមហាជនដែលអាស្រ័យនៅក្នុងបច្ចន្តគ្រាម(ស្រុកបាសាក់)ព្រមព្រៀងមូលគំនិតគ្នាបង្កើតឱ្យ មានជាបែបភាពតាមសម័យនិយម ដូចតទៅ ៖

-ទី១: ថ្ងៃពេញបូណ៌មី ខែអស្សុជ រដូវចេញវស្សា ត្រូវលេងទូកនៅពាមកន្ទោ ហៅថាពិធី បូជារំលឹកដល់ពុទ្ធបាទក្នុងទឹក។

-ទី២: ថ្ងៃពេញបូណ៌មី ខែកត្តិក ត្រូវលេងទូកនៅព្រែកអំពូយា ហៅថាពិធីសំពះព្រះខែ។

-ទី៣: ប្រជារាស្ត្រនៅឃុំនោះ តែជិតដល់ថ្ងៃកំណត់ ត្រូវនាំគ្នាសង់រោងមួយខ្នង ចំនួនបីល្វែងក្នុងទីវត្ត ជម្រះស្មៅឱ្យស្អាត ហើយរៀបចំសាលាមួយខ្នង លម្អទៅដោយភ្ញីផ្កា និងប្រទីបផ្សេងៗ ជាគ្រឿងរចនាទៅតាម បែបស្រុក។

-ទី៤: នៅថ្ងៃពេញបូណ៌មី ត្រូវមកឱ្យមូលគ្នា ដើម្បីនឹងប្រគេនចង្ហាន់ដល់ព្រះសង្ឃ ហើយរៀបចំបាពុំបី ល្វែងទៀត និងសាលាវត្តនោះ ឱ្យបានសមរម្យសម្រាប់ភ្ញៀវ។

-ទី៥: ដល់ម៉ោងពីររសៀល ត្រូវអុំសាកកម្លាំងគ្នាម្តង ដើម្បីនឹងរើសគូឱ្យត្រូវតាមល្បឿនគ្នា។

-ទី៦: ម៉ោង៥ នាម៉ឺនធំតូច អញ្ជើញទៅជួបជុំគ្នា ត្រូវអុំមួយគូម្តង យកឈ្នះចាញ់។

-ទី៧: ម៉ោង៦ ល្ងាច ទូក ង ទាំងអស់ ត្រូវចូលមកតម្រៀបគ្នានៅមុខបាពុំ ដើម្បីនឹងទទួលរង្វាន់។

-ទី៨: ម៉ោង៧ យប់ លៀងភោជនាហារដល់ពួកមន្ត្រីបម្រើការ ឯក្នុងវត្តមានលៀងភេសជ្ជៈ តែ កាហ្វេ ទឹកកកជាដើម ដល់ព្រះសង្ឃ។

-ទី៩: ម៉ោង៨ យប់ មានហែផ្កាភ្លើង ដោយក្បួនទូកបណ្តែតតាមទឹក និងមានអុជកាំជ្រួច រន្ទា ភ្ញី ទៀន។

-ទី១០: ម៉ោង៩ យប់ ចែករង្វាន់ដល់ទូកហែផ្កាភ្លើង ពេលនោះក្នុងទីវត្ត ឧបាសក ឧបាសិកា និមន្ត ព្រះសង្ឃចម្រើនព្រះបរិត្ត និងសម្តែងធម៌ទេសនា រហូតដល់ភ្លឺ។ ចំណែកមន្ត្រីបម្រើការ ក៏ត្រឡប់ទៅវិញ នៅ ពេលម៉ោងប្រាំបីប៉ុន្តែទូកងនៅលេងដល់ភ្លឺ។ព្រឹកឡើងថ្ងៃមួយរោជទើបនាំគ្នាប្រគេនចង្ហាន់ព្រះសង្ឃឆ្លងបញ្ចប់ បុណ្យ។ ឯពួកទូក ង ក៏បំបែកគ្នាទៅកាន់ទីស្ថានរៀងៗខ្លួនទៅ។

**កំណត់សម្គាល់:** ល្បែកប្រណាំងទូក ដែលយើងបានរៀបរាប់មកខាងលើនេះ គឺយើងបានសរសេរ តាមទំនៀមមកផងនិងតាមសារតោផងប៉ុន្តែរឿងទាំងនោះឃើញថាកាលជំនាន់បុរាណចាស់ទុំបានយកតម្រាប់ តាមកម្ពុជរដ្ឋទាំងអស់ លុះដល់សម័យឃ្លាតគ្នាឆ្ងាយ ក៏មានការវិបត្តិឃ្លៀងឃ្លាតខុសពីគ្នា ខ្លះៗ ដោយអន្លើ។ ពង្សាវតារនេះ សមាគមក្រុមយើងបានទៅស្រាវជ្រាវខ្ចីអំពីលោកចៅហ្វាយ អួង យកមកចម្លងទុកជាកេរតំណែ លតទៅ ដល់លោកចៅហ្វាយនោះអនិច្ចកម្មទៅ យើងក៏បានសងទៅកូនចៅលោក នៅភូមិកគោ ប៉ុន្តែភូមិនោះ ឥឡូវនេះឆេះខ្ទេចខ្ទីអស់ហើយ ។

រៀបរៀងដោយ - បណ្ឌិតសាស្ត្រាចារ្យ អ៊ុំ ថុង

## ១- បច្ចេកសព្ទអំពីទម្រង់ផ្សេងៗនៃកសិកម្ម

១-កសិកម្ម ការដាំដុះនិងការចិញ្ចឹមសត្វ។ eng. agriculture

២-កសិកម្មគោចរ/ កសិកម្មចល័ត ការដាំដុះនិងការចិញ្ចឹមសត្វដោយការផ្លាស់ប្ដូរទីកន្លែងទៅតាមលក្ខខណ្ឌភូមិសាស្ត្រ (ទឹក ដី ស្មៅ រដូវ...)។ eng. nomadic farming

៣-កសិកម្មចិញ្ចឹមពោះ កសិកម្មសម្រាប់ផ្គត់ផ្គង់ស្បៀងក្នុងគ្រួសារ ដើម្បីការរស់រានដោយមិនសំដៅសម្រាប់ការលក់ដូរឬធ្វើពាណិជ្ជកម្មទេ។ eng. agriculture of subsistence

៤-កសិកម្មឆ្លាតវៃ ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យាដែលជួយដល់ការកែប្រែនិងការរៀបចំប្រព័ន្ធកសិកម្ម ឱ្យស្របតាមបម្រែបម្រួលអាកាសធាតុ ដើម្បីធានានូវសន្តិសុខស្បៀង។ eng. smart agriculture

៥-កសិកម្មតាមកិច្ចសន្យា ផលិតកម្មកសិកម្មផ្អែកតាមកិច្ចសន្យារវាងអ្នកលក់និងអ្នកទិញដែលបានព្រមព្រៀងគ្នាទៅលើបរិមាណផ្គត់ផ្គង់ គុណភាពកសិផល ថ្លៃកសិផល ពេលវេលាទិញលក់ ការផ្ដល់បច្ចេកទេស ពូជ ជី ដើមទុនជាដើម។ eng. contract farming

៦-កសិកម្មនឹងកន្លែង/ កសិកម្មនិសិន្ន ការដាំដុះដែលកសិករធ្វើនៅកន្លែងដដែលៗ និងជារៀងរាល់ឆ្នាំក្នុងភូមិសាស្ត្រណាមួយ។ eng. sedentary agriculture

៧-កសិធុរកិច្ច ធុរកិច្ចខ្នាតធំដែលបម្រើឱ្យវិស័យកសិកម្មរួមបញ្ចូលទាំងផលិតកម្ម ការកែច្នៃ ការវេចខ្ចប់ ការចែកចាយផលិតកម្មកសិកម្ម ការផលិតគ្រឿងយន្តកសិកម្ម គ្រឿងសម្ភារៈបរិក្ខារផ្គត់ផ្គង់ឱ្យកសិកម្ម និងផលិតកម្មតាមកិច្ចសន្យា។ eng. agribusiness

៨-កសិកម្មប្រពៃណី កសិកម្មដែលធ្វើការដាំដុះនិងការចិញ្ចឹមសត្វបន្តពីជំនាន់មុន ដូចជារបៀបប្រើពូជ របៀបដាំដុះ ការប្រើកម្លាំងពលកម្ម (គោក្របី...) ហើយជាទូទៅ ទទួលផលតាមលក្ខខណ្ឌធម្មជាតិ។ eng. traditional agriculture

៩-កសិកម្មព្រៃដុត ការដាំដុះរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងព្រៃក្រាស់នៃតំបន់ត្រូពិក និងតំបន់ផ្សេងទៀត ដោយការកាប់ព្រៃហើយដុត និងដាំដំណាំជាចម្ការវិលជុំទៅតាមប្រពៃណីរបស់ខ្លួន។ eng. slash and burn agriculture

១០-កសិកម្មយថាផល ការដាំដុះឬការចិញ្ចឹមសត្វដែលប្រើទុននិងពលកម្មតិច ហើយទទួលបានផលតាមលក្ខខណ្ឌធម្មជាតិ។ eng. extensive agriculture

១១-កសិកម្មអតិផល ការដាំដុះឬការចិញ្ចឹមសត្វដែលប្រើទុននិងបច្ចេកទេសខ្ពស់ហើយទទួលបានទិន្នផលខ្ពស់ក្នុងផ្ទៃដី១ឯកតា។ eng. intensive agriculture

១២-កសិបសុកម្ម ការដាំដុះនិងការចិញ្ចឹមសត្វជាហ្វូងនៅតាមវាលស្មៅធម្មជាតិតាមបែបកសិកម្មចិញ្ចឹមពោះ។ eng. pastoral farming

១៣-កសិម្ហូបអាហារ សាខានៃផលិតកម្មឧស្សាហកម្ម ដែលមានមូលដ្ឋានលើការកែច្នៃផលិតផលកសិកម្ម រុក្ខជាតិ សត្វ ផលិតផលនេសាទនិងវារីវប្បកម្ម ដើម្បីផលិតចំណីអាហារសម្រាប់មនុស្សនិងសត្វ។ eng. agro alimentary

១៤-កសិអាកាសធាតុវិទ្យា ផ្នែកមួយនៃអាកាសធាតុវិទ្យា ដែលសិក្សាអំពីអាកាសធាតុតាមរយៈផលិតកម្មកសិកម្ម។ eng. agroclimatology/agricultural climatology

១៥-កសិឧតុភូតវិទ្យា ឧតុភូតវិទ្យាសិក្សាអំពីការប្រើប្រាស់ចំណេះដឹងនិងបច្ចេកទេសឧតុភូតនៅក្នុងវិស័យកសិកម្ម សំដៅបង្កើនទិន្នផលកសិកម្ម។
eng. agrometeorology/agricultural meteorology

១៦-កសិឧស្សាហកម្ម សំណុំនៃសហគ្រាសឧស្សាហកម្មដែលផ្ដល់នូវឧបករណ៍និងសម្ភារៈកសិកម្ម ( ជី និងថ្នាំកសិកម្ម គ្រឿងចក្រ... ) និងសហគ្រាសឧស្សាហកម្មដែលកែច្នៃ វេចខ្ចប់ និងបង្កើតលក្ខខណ្ឌឱ្យកសិផល ( ឧស្សាហកម្មកសិចំណីអាហារ )។ eng. agro-industry

១៧-បដិវត្តន៍កសិកម្ម ការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនូវរបៀបដាំដុះនិងការចិញ្ចឹមសត្វពីកសិកម្មតាមបែបប្រពៃណី ដើម្បីបង្កើនស្បៀងឱ្យបានច្រើន ក្នុងគោលបំណងដោះស្រាយសេចក្ដីត្រូវការរបស់ប្រជាជនដែលមានចំនួនច្រើនជាងមុន ហើយដែលចាប់ផ្ដើមនៅចក្រភពអង់គ្លេសក្នុងសតវត្សទី១៨។ eng. agricultural revolution

១៨-បដិវត្តន៍បៃតង ការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនូវបច្ចេកទេសដាំដុះ តាមរយៈអតិផលកម្ម ដូចជាការជ្រើសរើសពូជដំណាំ ការបង្កាត់ពូជ របៀបដាំ ធារាសាស្ត្រ ការប្រើជីនិងថ្នាំជាដើម ដើម្បីទទួលបានទិន្នផលខ្ពស់។បដិវត្តន៍នេះចាប់ផ្ដើមនៅប្រទេសម៉ិកស៊ិកក្នុងទសវត្សទី៥នៃស.វ.ទី២០។ eng. green revolution

---

ដោយ បណ្ឌិតសភាចារ្យ ឆយ អូន

# ២- ស្វែងយល់អំពីពាក្យ បណ្ដៅ

បណ្ដៅក៏ដូចជាសុភាសិតខ្មែរដែរបានបង្កប់នូវពុទ្ធិប្រជាប្រិយខ្មែរយើងយ៉ាងជ្រាលជ្រៅបំផុតអាចនិយាយបានថា វាជាគតិបណ្ឌិតប្រជាប្រិយខ្មែរ។ ដោយបណ្ដៅក៏ជាផ្នែកមួយនៃពាក្យចួនប្រជាប្រិយ ដូចនេះបណ្ដៅក៏ត្រូវតែមានលក្ខណៈបួនយ៉ាងដូចខាងក្រោមនេះដែរ ៖

**ក. ប្រធានបទ:** បណ្ដៅគឺជាកម្មវត្ថុនៃការបង្ហាញលក្ខណៈខាងក្រៅរបស់បាតុភូតនិងវត្ថុនានា ដែលយើងជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃ ហើយដែលនៅក្បែរៗយើង ទៅតាមលំដាប់កាលនៃប្រវត្តិសាស្ត្រ ដូចជា នង្គ័ល រនាស់ ត្បាល់បុក កង្កែប គោ ក្របី រុក្ខជាតិ ភ្លៀង ផ្គរ ព្រះអាទិត្យ ព្រះច័ន្ទ កណ្ដៀវ ប្រដាប់ប្រដាផ្ទះ ចំណែកមនុស្ស...។សព្វថ្ងៃនេះគេជួបប្រទះនឹងបណ្ដៅអំពីអគ្គិសនីផងដែរ«សត្វមួយរកស៊ីដូចខ្វែក ទំលើខ្សែដែកភ្នែកប៉ុនពងមាន់»។

បណ្ដៅមានច្រើនបែបណាស់ ៖

១- បណ្ដៅលើសត្វពាហនៈ សត្វរស់ក្នុងទឹក (កម្រលើសត្វព្រៃណាស់)

២- បណ្ដៅលើឧបករណ៍ប្រចាំគ្រួសារ ពលកម្ម សង្ខារិម...

៣- បណ្ដៅលើបាតុភូតធម្មជាតិ មានព្រះសុរិយា ព្រះច័ន្ទ្រា ព្រះភិរុណ ពិភពលោក តារា...

៤- បណ្ដៅរូបីកម្ម (មានដោយកម្រជាទីបំផុត)

**ខ. សិល្បវិធី:** បណ្ដៅចែកជាពីរផ្នែកមាន ៖

- ផ្នែកទីមួយសម្រាប់ទាយ
- ផ្នែកទីពីរសម្រាប់ឆ្លើយទៅនឹងបណ្ដៅនោះ

ចម្លើយគេដាក់នៅផ្នែកខាងក្រោយនៃសៀវភៅ ដើម្បីឲ្យអ្នកអានអ្នកស្ដាប់ទាយ។ ផ្នែកដែលសំខាន់គឺផ្នែកបណ្ដៅ។ រចនាសម្ព័ន្ធបណ្ដៅមានការពណ៌នា ពីលក្ខណៈខាងក្រៅរបស់វត្ថុក្រោមជ្រុងមួយផ្សេង។

ឧទាហរណ៍ : ឆ្អិនក្បាលស៊ីកន្ទុយ តើស្អីគេ? (បារី)

បណ្ដៅផ្ដល់នូវការសង្កេតមួយបែបទៀតចម្លែកគួរឲ្យអស់សំណើចទៅលើវត្ថុ។ការសង្កេតនេះវាខុសពីការសង្កេតតាមធម្មតា ជាពិសេសគេនិយមប្រើតទ្ធិតកម្ម(កម្លាយ)។

ឧទាហរណ៍ : មកពីឯងហ្នឹងបានជាអញវាយខ្លួនឯង តើស្អីគេ? (មូស)

**គ.មុខងារ:**បណ្ដៅជាទូទៅប្រើសម្រាប់កុមារពេលខ្លះមានបណ្ដៅមួយចំនួនសម្រាប់មនុស្សធំដែរតែមានចរិតសាមញ្ញគ្រោតគ្រាតអាសអាភាសដែលជាបណ្ដៅរូបីកម្ម។ បណ្ដៅផ្ដល់មេរៀនឲ្យកុមារ មេរៀនពីវត្ថុ បែបផែនពិនិត្យ ដើម្បីពង្រីកសមត្ថភាពសង្កេត ពង្រីកប្រឌិតកម្ម ហើយចងក្រងបានបាតុភូតប្លែកៗ។បណ្ដៅធ្វើឲ្យកុមារសប្បាយរីករាយ កាលណាគេរកឃើញចម្លើយត្រឹមត្រូវមួយ គេពន្យល់ពីចម្លើយនោះ។ សារសំខាន់គឺការពន្យល់

ពេលខ្លះអ្នកស្ដាប់ចម្លើយក៏មិនអាចយល់បានដែរត្រូវតែពន្យល់គេ។ម្យ៉ាងទៀតបណ្ដៅគឺជាលំហាត់គណិតវិទ្យាដែលមានចម្លើយច្រើន មានលទ្ធផលច្រើន។

ឧទាហរណ៍ : អង្គុយខ្ពស់ជាងឈរ តើស្អីគេ? ចម្លើយមានច្រើន (ឆ្កែ ឆ្មា ខ្លា ...)

ដូចនេះ គេចាត់ទុកថា ជាចម្លើយត្រូវចំពោះបាតុភូត សត្វ វត្ថុ ដែលគេស្គាល់ច្បាស់ជិតដិតមែនទែន។

**ឃ. មេបផែនសម្ដែង**: មនុស្សធំដាក់បណ្ដៅឲ្យកុមារ ប៉ុន្ដែពេលខ្លះកុមារចេះបណ្ដៅ ហើយក៏យកមកដាក់ឲ្យមនុស្សធំវិញដែរ។ប្រសិនបើមនុស្សធំមិនអាចរកចម្លើយឃើញកុមារត្រេកអរណាស់អញ្ចឹងហើយបានជាមនុស្សធំតែងធ្វើជាល្ងង់ ទុកឲ្យកុមារពន្យល់បណ្ដៅ។ គេមានទំនោរធ្វើចំណាត់ថ្នាក់បណ្ដៅទៅក្នុងផុលក្លរកុមារ។ កាលណាគេស្រាវជ្រាវបណ្ដៅប្រជាជាតិមួយ គេត្រូវរកឲ្យឃើញកូនសោទាំងអស់ ហើយកូនសោទាំងនោះត្រូវបើកឡើងនូវរចនាសម្ព័ន្ធទូទៅនៃបណ្ដៅទាំងអស់។

## ខ. នានាភាពនៃបណ្ដៅខ្មែរ :

### ង១. បណ្ដៅលើសត្វពាហនៈ ៖

- នៅផ្ទះស៊ីអាហារទាំងឡាយ គេប្រើទៅឆ្ងាយគេឲ្យស៊ីដែក។ តើស្អីគេ? (សេះ)
- ទៅលីទំពក់ មកលីទំពក់ ឬងក់ៗលីទំពក់ចូលព្រៃ។ តើស្អីគេ? (ឆ្កែ)
- នាងដើរដំណើរប្អូនស្រី យកដៃបោសដី បោសផ្កាសុភី។ តើស្អីគេ? (ដំរី)
- សត្វមួយមកពីជើង ក្បាលទើងមើង ជើងប៉ុនស្នប់។ តើស្អីគេ? (ដំរី)
- អង្គុយខ្ពស់ជាងឈរ ចុះមក៏ក្បាលមកមុន។ តើស្អីគេ? (ឆ្មា)

### ង២. បណ្ដៅលើបក្សី សត្វល្អិត ៖

- កំប៉េងកំប៉ោះ កំប៉េងឥតដោះ ចិញ្ចឹមកូនរស់។ តើស៊ីគេ? (មេមាន់)
- អត់ខ្មើយកើយខ្នង។ តើស្អីគេ? (ទា)
- សត្វមួយមក ពីខាងជើង ក្បាលដូចភ្លើង ជើងដុះស្នែង។ តើស្អីគេ? (មាន់គក)
- សត្វនោះមកពីស្រុកបាសាក់ កន្ទុយបិទប្រាក់បិទមាសសងខាង។ តើស្អីគេ? (ក្ងោក)
- សត្វមួយមកពីស្រុកខាងលិច ប្រិចៗស៊ីបាយមុនលោក។ តើស្អីគេ? (រុយ)
- នាងតីនាងតៀវ ចង្កេះរាងរៀវ ធ្វើផ្ទះចុងឈើ។ តើស្អីគេ? (អង្រ្កង)
- នាងអើយនាងស្រី ពេលចេញរកស៊ី យកគូថដោះស្រាយ។ តើស្អីគេ? (ពីងពាង)
- ខឹងនឹងគេ វាយខ្លួនឯង។ តើស្អីគេ? (មូស)

### ង៣ . បណ្ដៅលើរុក្ខជាតិ ធញ្ញជាតិ ៖

- ព្រឹក្សាដុះនាក្បែរផ្លូវ អ្នកផងដើរទៅ ហៅឯងឆ្លើយឯង។ តើស្អីគេ? (ត្នោតបាត)
- ព្រឹក្សាបន្លារយពាន់ មានថ្នាំងកង់ៗ ដុះដៃពីភ្នែក។ តើស្អីគេ? (ឫស្សី)
- ព្រឹក្សាផល្លានាមហៅ ពកូនពចៅ ពលរេហ៍សងខាង។ តើស្អីគេ? (ស្លា)

- ដើមវាប៉ុនសសរ ស្លឹកវាប៉ុនក្ដារកី។ តើស្អីគេ? (ចេក)
- ដើមវាប៉ុនទៀន លៀនឡើងប៉ុនថាស។ តើស្អីគេ? (ឈូក)
- ដើមវាប៉ុនសរសៃអំបោះ ស្លឹកវាកំប៉ោះ ផ្លែវាចាក់ក្បាច់។ តើស្អីគេ? (ម្រះ)
- ដើមវាតែ ផ្លែវាតាន់ យកដៃកាន់ ប៉េកប៉កពៅអើយ។ តើស្អីគេ? (ចំបក់)
- ដើមវាកន្ទ្រៃរ៉ែ ផ្លែវាកន្ទឹតម៉ោង។ តើស្អីគេ? (ម្ទេស)
- រុក្ខាឈ្មោះថាមិនក្រ ទោះគ្មានផ្កាផ្លែល្អ ក៏នៅមិនអត់។ តើស្អីគេ? (មៀន)
- ព្រឹក្សាដុះប្របផ្លូវ អ្នកផងដើរទៅ ឲ្យថ្លៃមុនទិញ។ តើស្អីគេ? (ម្កាក់)
- ព្រឹក្សាដុះក្បែរផ្លូវ អ្នកផងដើរទៅ ថាវាកាចណាស់។ តើស្អីគេ? (ដំបងយក្ស)
- ពីតូចល្អម្ដង ដល់ចាស់កោងខ្នង រឹតល្អម្ដងទៀត។ តើស្អីគេ? (ស្រូវ)
- ព្រឹក្សាដុះព្រៃជ្រៅ អ្នកផងដើរទៅ ថាវាមកថ្មី។ តើស្អីគេ? (ត្នៀវ)
- ពីតូចទូលដី ធំឡើងដឹងក្ដី ស្រាតសំពត់ទូលក្បាល។ តើស្អីគេ? (ទំពាំង)
- រុក្ខានាមបក្សី មិនដែលចេះស្ដី ចេះផ្ញើនឹងគេ។ តើស្អីគេ? (បញ្ញើក្អែក)
- មានភ្នែកឥតប្រស្រី ដុះចេញពីដី ដើមវាទ្រផ្លែ។ តើស្អីគេ? (ម្នាស់)
- ផ្កានៅឯចុង ផ្លែនៅឯគល់។ តើស្អីគេ? (សណ្ដែកដី)
- កំប៉ុកក្រពុំ អង្គុយលើភ្នំ រំសាយសក់លេង។ តើស្អីគេ? (ពោត)
- ទឹកមួយថ្លុក កំពឹសពងពេញ។ តើស្អីគេ? (ផ្លែក្រូច)

## ង៤. បណ្ដៅលើសត្វរស់ក្នុងទឹក ៖

- អាបួនសៃងទូ អាំទំពែកកៅស៊ូ រុញដកៗ។ តើស្អីគេ? (អណ្ដើក)
- អាមាត្យប្រាំបី មន្ត្រីពីរ លីហិបមួយ។ តើស្អីគេ? (ក្ដាម)
- តែលតោលកណ្ដាលបឹង ដុះស្នែងកញ្ជ្រឹង ដល់ដីមិនមុត។ តើស្អីគេ? (ខ្យង)
- កំប្លុកកំប្លូវ អង្គុយក្បែរផ្លូវ ពាក់អាវព្រៃរួញ។ តើស្អីគេ? (គីង្គក់)
- ឯកអង្គទ្រង់នាមបញ្ចវគ្គ ភ្នែកលៀនស្មើរថ្ពាល់ ដៃធំជាងជើង។ តើស្អីគេ? (បង្កង)

## ង៥. បណ្ដៅលើឧបករណ៍ប្រើប្រាស់ ៖

- ស្ដេចក៏ចាយបាន រាស្ត្រក៏ចាយបាន។ តើស្អីគេ? (ចានបាយ)
- នាងលើកជើងធាក់ ទាំងក្បាលអ្នកស្ដេច។ តើស្អីគេ? (មុង)
- នាងធូរនាងធាត់ នាងធូរឥតមាត់ នាងធូរធាត់ឯង។ តើស្អីគេ? (ខ្នើយ)
- គេប្រើវាចិត(ធាត់) គេអាណិតវាស្គម។ តើស្អីគេ? (បាវ-ការុង)
- នាងអើយនាងនង មាត់ធំច្រហា អណ្ដាតក្រហម។ តើស្អីគេ? (ចង្ក្រាន)
- ក្រពើមិនជិះ ទៅជិះគល់ឈើ ក្បាលដូចគេរើ អាចម៍ដូចគេរាយ។ តើស្អីគេ? (ខ្ទោស)
- ស៊ីនឹងចំពុះ ដល់ជុះនឹងស្លាប។ តើស្អីគេ? (នង្គ័ល)
- ទាញតែវល្លិ៍មួយ រញ្ជួយគ្រប់មែក។ តើស្អីគេ? (រហាត់ទឹក)

- កូក់ដូចកទុង កូងដូចកន្ទាត រកស៊ីសង្វាត រកពោះដាក់គ្មាន។ តើស្អីគេ? (កណ្ដៀវ)
- ឫស្សីមួយគុម្ព ជ្រំកណ្ដាលស្ទឹង។ តើស្អីគេ? (អង្រុត)
- ទៅស្គមមកធាត់។ តើស្អីគេ? (ទ្រុងដាក់ត្រី)
- ឈើមូលមួយដុំ ជំនុំគ្នាមិនដាច់។ តើស្អីគេ? (ប្រអប់ស្លា)
- ទុកចោលវាចាស់ ប្រើណាស់វាថ្មី។ តើស្អីគេ? (កាំបិត)
- ឈើកោងដាក់លើឈើកាង អារក្សជាន់ជាងគ្រវីខ្វាត់ខ្វាយ។ តើស្អីគេ? (ត្បាល់កិន)
- គុកគុលមមុលក្រោមដី សត្វជើងប្រាំបី នាំមុខគុកគុល។ តើស្អីគេ? (នង្គ័ល)
- បោះទៅប៉ុនអំពក ទាញមកប៉ុនបំពង់។ តើស្អីគេ? (សំណាញ់)
- ស៊ីពីពោះជុះពីខ្នង។ តើស្អីគេ? (ដែកឈូស)
- មានជើងមួយ ខ្សែទាញស្ទែងបី ភាពដូចស្រី មានដោះខាងឆ្វេង
មានធ្នូមិនដែលបាញ់លេង បាញ់តែខ្លួនឯង សូរសៀងស្រងាត់។ តើស្អីគេ? (ទ្រខ្មែរ)
- កូនអូរតូចមួយ បងមិនហ៊ានឆ្លង កំពៅមាសបង ឆ្លងទៅឆ្លងមក។ តើស្អីគេ? (ត្រល់)
- ឃ្លោកមិនឃ្លោក ល្ពៅមិនល្ពៅ ដាក់លើភ្លៅ កន្រ្ទឹមបាយចូក។ តើស្អីគេ? (ស្គរ)
- ដីមួយដុំ ផ្កាមួយគុម្ព ពស់ពេនលើ។ តើស្អីគេ? (ស្គរអារក្ខ)
- វាយគោធំពីរ ស៊ីជុំរទេះ វាយកូនគោប្រឡាក់ផេះ កេះដោះក្រមុំ
អុំទូក ង។ តើស្អីគេ? (វង់ពិណពាទ្យ)

ង៦. បណ្ដៅលើសកម្មភាពជីវភាពប្រចាំថ្ងៃ ៖

- វាយអារស់ អាងាប់ស្រែក។ តើស្អីគេ? (បររទេះ)
- ជើងដប់ប្រសព្វជើងមួយ ភ្នែកប្រាំមួយប្រមាណថា តែកតោកដូច
អ្នកស្រវឹងស្រា គ្មានអ្នកណាថា ថាតែម្នាក់ឯង។ តើស្អីគេ? (ភ្ជួរស្រែ)
- កៀកកលៀនអណ្ដាត។ តើស្អីគេ? (សិតទឹកពីត្នោម)
- ដាមអើយស្រីដាម ទឹកភ្នែករហាម គេចាប់ដាមចង ក្រមុំពីរនាក់
ដើរតាមគន្លង គេចាប់ដាមចង នៅកោះអន្លង់កី។ តើស្អីគេ? (ត្បាញសំពត់)
- កាត់កឥតឈាម កាត់ដៃឥតស្រមាម ពុះទ្រូងឥតថ្លើម។ តើស្អីគេ? (កាត់អារ)
- ខិតឡើងលើ ខិតចុះក្រោម ល្មមហើយអ្នក។ តើស្អីគេ? (ថ្លឹងអីវ៉ាន់)
- ទឹកអូរហូរភើង ដំរីងាប់ស្ដឹង កណ្ដាលទឹកអូរ។ តើស្អីគេ? (ដាក់លប)
- កាន់កន្ទុយញាក់ខ្សែ អាចម៍មួយស្រែ មិនស្អុយសោះ។ តើស្អីគេ? (ភ្ជួរដី-អាចម៍បំណះ)
- ក្រុកៗមាន់ក្រាប យកដៃស្ទាប ម៉ែអើយប៉ុន្មាន?។ តើស្អីគេ? (វាល់អង្ករដាំបាយ)
- វេញកន្ទុះខ្ទុះអាញុំញ។ តើស្អីគេ? (ដោតចេសចូលម្ជុល)
- ចាស់និងចាស់ប្រទះគ្នា។ តើស្អីគេ? (ប៉ះខោអាវ)
- ជើងបួនចុះក្រោម ជើងបួនឡើងលើ ក្បាលបីងីងើ ងាកមើលកន្ទុយ។ តើស្អីគេ? (សែងជ្រូក)

- ស្រីសល្អបងអើយ ងូតទឹករួចហើយ នាំគ្នាចូលដេក។ តើស្អីគេ? (លាងចានយកទៅផ្កាប់)
- អាសម្រិទ្ធចុកក្ដិតអាសម្រេង លើកឡើងក្របាមវែងកៀរលិទ្ធៗ។ តើស្អីគេ? (ស៊ុស្លាម្ហូ)

ង៧ . បណ្ដៅលើបាតុភូតធម្មជាតិ ៖

- ចាំងមួយថ្ងៃរាល់ល្ងាច រករកាច់បន្តិចគ្មាន។ តើស្អីគេ? (ព្រះអាទិត្យ)
- ដាក់ទ្រូលើចុងឫស្សី មិនត្រូវត្រីអី ត្រូវនាងកំប្លង់ៗ។ តើស្អីគេ? (ព្រះច័ន្ទពេញវង់)
- បោះសន្ទូចរំលងភ្នំ ត្រីឆ្តោមាត់ធំ ដេញលេបក្អោកមាស។ តើស្អីគេ? (រាហ៊ូចាប់ច័ន្ទ)
- លាចមួយកញ្ជ្រែង រាយគ្រប់ទាំងស្រុក។ តើស្អីគេ? (ផ្កាយ)
- នួនអើយនាងនួន នាងធំតែខ្លួន តែទាបជាងស្មៅ។តើស្អីគេ? (ផែនដី)
- ត្រប់ទុំត្រប់ទែង ខាងលិចស្រែវែង ឥតអ្នកណាដើរដល់។ តើស្អីគេ? (ជើងមេឃ)
- មានជើងឥតខ្នង មានខ្នងឥតពោះ មានច្រមុះឥតភ្នែក។ តើស្អីគេ? (ជើងភ្នំ ខ្នងភ្នំ ច្រមុះភ្នំ)
- ឥតដើមឥតមែក ផ្លែជ្រែកនៅដី។ តើស្អីគេ? (ក្រួស)
- ឈើកោងរំលងភ្នំ ត្រដេវិចយំ ជ្រងស្រងាត់។ តើស្អីគេ? (ឥន្ទធនូ)
- ដូងមួយចំណិតចិតទើរ។ តើស្អីគេ? (លោកខែ)
- ដើមមួយត្រួយបួន ផ្កាជុំខ្លួន ផ្លែតែពីរ។ តើស្អីគេ? (ផែនដី ទិសទាំងបួន ផ្កាយ សុរិយា ចន្ទ្រា)

ង៨. បណ្ដៅធៀប ៖

- ស៊ីដេក ស៊ីដេក ដូចជ្រូក។ តើស្អីគេ? (ពួកអ្នកមាន)
- ក្បាលពោះឡើងពើង ជញ្ជក់ឈាមរាស្ត្រដូចឈ្លើង។ តើស្អីគេ? (ពួកនាម៉ឺនពុករលួយ)
- ចាស់មិនព្រមទុំ។ តើស្អីគេ? (ចាស់ខិល)
- គ្រុនទន្សាយ។ តើស្អីគេ? (អ្នកឈឺពុត)
- ក្រពើវង្វេងបឹង។ តើស្អីគេ? (អ្នករមិលគុណ)

ង៩. បណ្ដៅរូបីកម្ម ៖

- ដាក់ថ្នាំនៅចុង ដល់រុញចូលក្នុង បែកពពុះស្គុល។ តើស្អីគេ? (ដុះធ្មេញ)
- អង្គុយចោងហោង ទំនងខ្ទុត ខ្លាចមិនមុត យកដៃស្ទាប។ តើស្អីគេ? (សំលៀងកាំបិត)
- អ្នកក្រោមស្រណុក អ្នកលើកើតទុក្ខ បះដៃបះជើង។ តើស្អីគេ? (អុំទូកឬចែវទូក)
- អ្នកក្រោមស្រណុក អ្នកលើកើតទុក្ខ បះដៃបះជើង។ តើស្អីគេ? (អុំទូកឬចែវទូក)
- ហុចឲ្យឡាន ច្រានទៅមុខ ពេលចង់ឈប់ កេះគូចឯង។ តើស្អីគេ? (ជាក់ស៊ីក្លូ)
- អាច្រមក់ មុខអាក្រក់ ស៊ីតែសាច់ ស៊ីមិនដាច់ ជញ្ជក់ទឹក។ តើស្អីគេ? (កូនបៅដោះ)
- ជន្លួញក៏សាច់ ដំណាប់ក៏សាច់ ដាក់ប៉ាច់ចេញទឹកច្រូច។ តើស្អីគេ? (កូនបៅដោះ)
- សត្វមួយហើរលើអាកាស ស្រែកខ្លាំងណាស់ខ្ទ័រផែនដី។ តើស្អីគេ? (យន្តហោះ)
- សត្វមួយមានភ្នែកបី ទោះមន្ត្រីក៏ខ្លាចដែរ។ តើស្អីគេ? (ភ្លើងស្តុប)

- អ្នកទាំងបួន ជូនឈ្មោះតែមួយ អ្នកបីពងស្រួយ
អ្នកមួយពងទន់។ តើស្អីគេ? (ក្អែកគោក ក្អែកទឹក អណ្តើកក្អែក ត្រីក្អែក)

- ពេលព្រឹកដើរជើងបួន ថ្ងៃត្រង់ដើរជើងពីរ រសៀលដើរជើងបី។ តើស្អីគេ? (ទារក យុវជន ជរា)

- មេស្រែកគប់ៗ កូនវាទាំងគ្រប់ ធ្លាក់ឲ្យរពុយ។ តើស្អីគេ? (កាប់ឈើ)

- ឯកអង្គទ្រង់នាមបក្សី កន្ទុយអូសដីពាំឈើហោះលេង។ តើស្អីគេ? (បង្ហោះខ្លែង)

-អាគ្រហូពីក្រោម អាមូលពីលើ ក្បាលងោកងីងើ បែកញើសរហាម។ តើស្អីគេ? (បុកអង្ករ)

- សំយាកសំយុង ទន្លេបួនជ្រុង លូកដៃមិនដល់។ តើស្អីគេ? (កញ្ចក់ឆ្លុះមុខ)

- ស្ទាបក្បាល ទះពោះ។ តើស្អីគេ? (វាយស្គរ)

- សអើយស្រីស កូនរាប់ដំប នៅឆ្ងាយពីគ្នា ឲ្យម្តាយកើតទុក្ខ
លំបាកវេទនា ដើរអើតគ្រប់គ្នា ទម្រាំគ្រប់កូន។ តើស្អីគេ? (អន្ទងអំបោះ)

- គោក្របាមលិទ្ធក្តិតគោខ្មៅ។ តើស្អីគេ? (ដាំបាយ)

- នាងអើយនាងនី មានភ្នែកដប់ពីរ ងាប់មិនដែលស្អុយ។ តើស្អីគេ? (នាឡិកា)

- ទឹកមួយថ្លុក កូនជ្រូកដេកពេញ។ តើស្អីគេ? (ស្ងោរនំអន្សម)

- ចាប៉ីខ្សែមួយ មិនព្រួយរិតផ្សំ លើកដាក់ឲ្យចំ ស៊ីសាច់រាប់នាឡិ។ តើស្អីគេ? (ថ្លេចសំឡី)

- ម៉ែរុញ កូនទាញ។ តើស្អីគេ? (ចែវទូក)

## កង្កែបចង់បានស្តេច ( ពាក្យ៧ )

វស្សន្តដើមឆ្នាំនាមាត់ស្រះ ចន្ទថ្លាត្រចះចោលរស្មី
ជះចំវារីបែតងខ្ចី លម្អរាត្រីនៃចន្ទ្រា។
ក្អុកក្អាត់កង្កែបយំអឹងកង រីករាយកន្លងប្រឡែងគ្នា
ស្រាប់តែសំលេងខ្ទ័រគង្គា គ្រប់គ្នាម្ទីម្នាផ្ទៀងចាំស្តាប់។
នែ៎រ៉ឺយកង្កែបចូរចាំណា ចង់រស់សុខាត្រូវមានច្បាប់
អាងតែគ្នាឯងឥតសណ្តាប់ បន់សុំប្រញាប់ស្តេចពូកែ។
ពពួកមណ្ឌុកស្រែកព្រមគ្នា អង្វរទេវាជួយថ្ងៃប្រែ
ផ្តល់ស្តេចមួយអង្គបានដង្ហែ ដឹកនាំថ្នមថែដូចបំណង។
រំពេចនោះសំណាក់ឈើខ្មៅ បោះពួយសំដៅកន្លែងផ្សង
កង្កែបតោងឡើងជិះឈើម្តង លោតទន្ទ្រាំផងឈើឥតថា។
ស្លូតណាស់ស្ពឹកណាស់ត្រួតមិនកើត កង្កែបចើតមើតផ្ងង់វាចា
សូមអម្ចាស់សួគ៌ព្រះមេត្តា យើងសូមតវ៉ាប្តូរស្តេចថ្មី។
អស្ចារ្យគ្រានោះលេចសត្វស្លាប ហិចហើរឆៀងឆាបជិតដល់ទី
កង្កែបស្វាគមលោតរក់រី សាទរភូមីមកគ្រប់គ្រង។
ក្រឡេកក្រឡាប់បក្សីស្រែក ចុមប៉ែចម្លែកអស់ទាស់ហ្មង
មានតូចមានធំបែបទំនង ពេលនេះអញហោងឃ្លានភោក្តា។
ក្រៀលបន្ទាបខ្លួនមិនបង្អង់ ត្រដាងស្លាបត្រង់បើកចង្កា
លេបកង្កែបឆីឆ្ងាញ់ពិសា ខ្លះក៏មរណាខ្លះចោលទី។
នេះឬកង្កែបប្រជាធិបតេយ្យ ស្អប់ចាស់ប្តូរថ្មីភ័យញាំញី
គិតគ្នាសាងសុខប្រឹងសំភី ពូនជ្រុំសាមគ្គីជាតិរុងរឿង។

## ល្បើកទន្សាយនិងត្រីរ៉ស់

ថ្ងៃមួយ ទន្សាយភ្លេចខ្លួនត្រូវជាប់អន្ទាក់របស់បុរសម្នាក់។ គាត់យកវាទៅក្រុងទុកក្នុងអង្រុត នៅប្រេបនឹងថ្លាងមួយដែលមានប្រស់ត្រីរ៉ស់។

ទន្សាយបានប្រាប់ទៅត្រីរ៉ស់ថា ៖

ចូរឯងធ្វើពុតជាស្លាប់ផ្ងារពោះឡើងលើ ពេលគេចាប់ឯងយកទៅស្រកា ឯងត្រូវបម្រះលោតទៅក្នុងទឹកនោះទៅ រួចហែលរេរាបន្តិចសិន។

ត្រីរ៉ស់សួរទៅទន្សាយវិញថា ៖ ចុះអ្នកឯងវិញគិតយ៉ាងណាដែរ?

ទន្សាយឆ្លើយថា ៖

គេនឹងមកយកអង្រុតទៅរុតយកឯងមកវិញ គ្នាក៏រួចខ្លួនដោយសារឯងដែរ។ បុរសមានត្រីរ៉ស់មួយទន្សាយមួយសម្រាប់ធ្វើម្ហូប។ គាត់ធ្លាប់ឮគេនិយាយថា មានលោកសង្ឃមួយអង្គនៅវត្តនេះ ពូកែចាប់យាមផុតណាស់។

បុរសថ្វាយបង្គំលោករួចពិតពុទ្ធដីកាថា ៖ ខ្ញុំព្រះករុណាឮល្បីថាលោកគ្រូចេះចាប់យាមផុតណាស់!។

ព្រះសង្ឃមានពុទ្ធដីកាតបវិញថា ៖ ចេះ! ប៉ុន្តែត្រង់ផុតឬមិនផុតអាត្មាមិនហ៊ានអួតទេ។

បុរសបានទូលលោកថា៖សុំលោកគ្រូទាយបន្តិចទៅមើលតើថ្ងៃនេះខ្ញុំករុណាមានលាភអ្វីទេ?

លោកគ្រូរាប់ម្រាមដៃចុះឡើងក៏មានសង្ឃដីកាថា៖ញោមគ្មានលាភអ្វីទេថ្ងៃនេះបើតាមជើងលេខវិញលិទ្ធថ្មចង្ក្រាន។

បុរសញញឹមបែបចំអក ក៏ថ្វាយបង្គំលាលោកគ្រូត្រឡប់មកផ្ទះវិញទាំងស្រដីថា ៖ ថ្ងៃត្រង់នេះ ខ្ញុំករុណានឹងឱ្យអ្នកផ្ទះខ្ញុំករុណាយកចង្ហាន់មកប្រគេន ខ្លាចតែលោកគ្រូលិទ្ធមាត់ទេ។ ពីរនាក់ប្ដីប្រពន្ធ ក៏ចាប់ត្រីយកទៅស្រកានៅមាត់ត្រពាំង ត្រីរ៉ស់ស្ទុះរួចពីដៃលោតផ្លូចចូលទៅក្នុងទឹកវានៅហែលរេៗប៉ប្រះផ្ទៃទឹកបុរសស្ទុះរឹងទៅយកអង្រុតមករុតត្រីភ្លេចគិតថាមានទន្សាយនៅក្នុងអង្រុត។ទន្សាយក៏បោលប្រូចចូលគម្ពោតព្រៃបាត់។ឡើងពីទឹកមកវិញគាត់រងាញ័រមាត់មកអង្គុយអាំង ភ្លើងចង្ក្រានដែលបង្កាត់ចោល។ ប្រពន្ធនឹកហួសចិត្តទម្លាក់គូថអង្គុយប្របប្ដី ប្ដីខ្លាចភ្លើងឆេះជាយសំពត់ក៏លូកដៃទៅកេះប្រពន្ធប្រាប់ប៉ុន្តែត្រូវប្រពន្ធគៀសដៃចេញប៉ះចុងម្រាមនឹងថ្មចង្ក្រានកំពុងក្ដៅ ក៏រវាសយកម្រាមដៃបៀមក្នុងមាត់ទៅ។



ប្រាសាទបាយ័ន



ប្រាសាទកោះកេរ